# មាតិកា ទំព័រ


១-ពិធីអធិដ្ឋានសម្រាប់អ្នកជិតផុតដង្ហើម.......................................... ១-១២

២-ពិធីអធិដ្ឋានសម្រាប់អ្នកទើបផុតដង្ហើម........................................ ១៣-១៧

៣-ពិធីអធិដ្ឋានសម្រាប់វិញ្ញាណក្ខ័ន្ធអ្នកស្លាប់ ..................................... ១៨-២៩

៤-ពិធីដាក់សពក្នុងមឈូស ......................................................... ៣០-៣៨

៥- ពិធីដង្ហែសពចេញពីផ្ទះទៅព្រះវិហារ ........................................... ៣៩-៤០

៦-អភិបូជាពេលសពតម្កល់នៅក្នុងព្រះវិហារ ....................................... ៤១-៥៥

៧-ពិធីលាសពចុងក្រោយ.............................................................. ៥៦-៦១

៨- ពិធីនៅឈាបនដ្ឋាន ឬទីបញ្ចុះសព ............................................ ៦២-៦៥

៩ - ពិធីជូនភ្លើងសព ឬ រំកិលសពចូលក្នុងរណ្ដៅ............................... ៦៦-៦៧

១០- ពិធីតម្កល់អដ្ឋិធាតុក្នុងចេតិយ .................................................. ៦៨-៧២

# ១ ពិធីអធិដ្ឋាន សម្រាប់អ្នកជិតផុតដង្ហើម

►*អ្នកចូលរួមធ្វើសញ្ញាឈើឆ្កាងលើថ្ងាស ជាមួយទឹកព្រះពរ ដើម្បីរំឭកពីអគ្គសញ្ញាជ្រមុជទឹក ដែលខ្លួនបានទទួលជីវិត ទាំងផ្ញើជីវិតលើព្រះគ្រីស្តផង។*

## *របៀបទី ១*

### ១- ពិធីប្រារព្ធ

►*នៅស្ងាត់បន្តិច*

### ២- ពាក្យអធិដ្ឋាន

បពិត្រព្រះយេស៊ូគ្រីស្តជាអម្ចាស់ ព្រះអង្គបានរងទុក្ខលំបាកព្រោះតែអំពើបាបរបស់យើងខ្ញុំ សូមទ្រង់ព្រះមេត្តាប្រោសអាណិតអាសូរ និងលើកលែងទោសឱ្យ.............. (ឈ្មោះជាគ្រីស្តបរិស័ទ) ផង។

នៅពេលនេះ.............. (ឈ្មោះជាគ្រីស្តបរិស័ទ) កំពុងមានទុក្ខលំបាកយ៉ាងខ្លាំង យើងខ្ញុំសូមអង្វរព្រះអង្គ សូមព្រះមេត្តាផ្តល់កម្លាំងដល់គាត់ផង។ ឱ! សន្តីម៉ារីជាមាតាព្រះអម្ចាស់ សូមជួយអង្វរព្រះអង្គឱ្យ.............. (ឈ្មោះជាគ្រីស្តបរិស័ទ) ជាអ្នកបាបនៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

## ៣- ធម៌ ទទួលសារភាព

ច- សូមបងប្អូនទទួលសារភាពថា យើងជាអ្នកមានបាប និងសូមព្រះអម្ចាស់រំដោះបាបឱ្យយើង។

គ- ខ្ញុំសូមទទួលសារភាពចំពោះព្រះដ៏មានតេជានុភាពសព្វប្រការ
ហើយចំពោះអស់បងប្អូនផងថា
ខ្ញុំជាអ្នកមានបាបច្រើន
ដោយកាយវាចាចិត្ត
និងដោយខានប្រព្រឹត្តកិច្ចការរបស់ខ្ញុំ។

*ទោសខ្ញុំអើយ ! ទោសខ្ញុំអើយ ! ទោសខ្ញុំអើយ ! ធ្ងន់ណាស់។*

ហេតុនេះ សូមព្រះនាងព្រហ្មចារិនីម៉ារី អស់ទេវទូត និងសន្តបុគ្គលទាំងឡាយ ព្រមទាំងអស់បងប្អូន សូមជួយអង្វរព្រះអម្ចាស់ឱ្យខ្ញុំផង។ *អាម៉ែន។*

## ៤- ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

### ក- ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

- *រដូវធម្មតា*

**អាលេលូយ៉ា** ! សូមលើកតម្កើងព្រះយេស៊ូ ដែលទ្រង់បានឈ្នះសេចក្ដីស្លាប់ ចូរយើងទទួលដោយសប្បាយ ជីវិតថ្មីពីព្រះអម្ចាស់ **អាលេលូយ៉ា**។

- *រដូវអប់រំពិសេស*

*បន្ទរ ៖* សូមលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ដ ព្រះអង្គជាព្រះពន្លឺ នៃព្រះជាម្ចាស់ សូមកោតសរសើរព្រះអង្គ។

ឱ! ព្រះជាម្ចាស់ សូមព្រះមេត្តាអាណិតអាសូរ កែប្រែដួងចិត្ត គំនិតយើងខ្ញុំ ដើម្បីទទួល ព្រះសង្គ្រោះយើង។

## ខ- សូមថ្លែងព្រះគម្ពីរដំណឹងល្អ តាមសន្តៈ យ៉ូហាន *(យហ ១៤, ១-៦)*

ព្រះយេស៊ូមានព្រះបន្ទូលថា៖"កុំរន្ធត់ចិត្តធ្វើអ្វី អ្នករាល់គ្នាជឿលើព្រះជាម្ចាស់ហើយ សុំជឿលើខ្ញុំផង។ ក្នុងដំណាក់របស់ព្រះបិតាខ្ញុំ មានលំនៅជាច្រើន។ បើពុំដូច្នោះទេ ខ្ញុំមិនបានប្រាប់អ្នករាល់គ្នាថា ខ្ញុំទៅរៀបចំកន្លែងទុកឱ្យអ្នករាល់គ្នាឡើយ។ ពេលខ្ញុំទៅរៀបចំកន្លែងទុកឱ្យអ្នករាល់គ្នាហើយ ខ្ញុំនឹងត្រឡប់មកវិញ យកអ្នករាល់គ្នាទៅជាមួយខ្ញុំ ដើម្បីឱ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅ។ ឯកន្លែងដែលខ្ញុំទៅនោះ អ្នករាល់គ្នាក៏ស្គាល់ផ្លូវទៅដែរ"។ លោកថូម៉ាសទូលព្រះអង្គថា៖ "បពិត្រព្រះអម្ចាស់ ធ្វើដូចម្ដេចឱ្យយើងខ្ញុំអាចស្គាល់ផ្លូវទៅបាន បើយើងខ្ញុំមិនដឹងថា ព្រះអង្គយាងទៅទីណាផងនោះ?"។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ "ខ្ញុំហ្នឹងហើយជាផ្លូវ ជាសេចក្ដីពិត និងជាជីវិត។ គ្មាននរណាម្នាក់អាចទៅកាន់ព្រះបិតាបានឡើយ លើកលែងតែទៅតាមរយៈខ្ញុំ។ បើអ្នករាល់គ្នាស្គាល់ខ្ញុំ អ្នករាល់គ្នាក៏ស្គាល់ព្រះបិតារបស់ខ្ញុំដែរ។ ឥឡូវនេះ អ្នករាល់គ្នាស្គាល់ព្រះអង្គហើយ ព្រមទាំងបានឃើញព្រះអង្គថែមទៀតផង"។

**ឲ**- នេះជាព្រះបន្ទូលដំណឹងល្អ របស់ព្រះយេស៊ូគ្រីស្ត ជាអម្ចាស់ !

## ៥- ធម៌ ប្រកាសជំនឿ របស់គ្រីស្តទូតទាំងឡាយ

- ខ្ញុំជឿលើព្រះបិតាដ៏មានតេជានុភាពសព្វប្រការ
  ជាព្រះបង្កើតមេឃ និងដី។
- ខ្ញុំជឿលើព្រះយេស៊ូគ្រីស្ត
  ជាព្រះបុត្រាតែមួយនៃព្រះបិតា
  ហើយជាអម្ចាស់យើងខ្ញុំ។

ព្រះអង្គបានចាប់កំណើតជាមនុស្ស ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ

ហើយទ្រង់បានប្រសូត ពីព្រះនាងព្រហ្មចារិនីម៉ារី

ព្រះអង្គបានសោយទុក្ខលំបាក នៅជំនាន់លោក **ប៉ុនពីឡាត**។

ព្រះអង្គត្រូវគេឆ្កាង សោយព្រះទិវង្គត

ហើយព្រះសពព្រះអង្គ ត្រូវគេបញ្ចុះក្នុងរូងថ្មមួយ។

ព្រះអង្គបានយាងចុះទៅស្ថានក្រោម

លុះដល់ថ្ងៃទី ៣ ទ្រង់មានព្រះជន្មរស់ឡើងវិញ

រួចព្រះអង្គបានយាងឡើងស្ថានបរមសុខ

ទៅគង់ខាងស្ដាំព្រះបិតា ដ៏មាន តេជានុភាពសព្វប្រការ។

ព្រះអង្គនឹងយាងមកវិញ ដើម្បីកាត់ក្ដីបាបកុសល

ឱ្យមនុស្សទាំងរស់ទាំងស្លាប់។

- ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ ខ្ញុំជឿលើព្រះសហគមន៍កាតូលិក

និងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ

ខ្ញុំជឿថា មានការលើកលែងទោសរំដោះបាប

ហើយរូបកាយមនុស្សនឹងរស់ឡើងវិញ

ព្រមទាំងមានជីវិតរស់នៅ អស់កល្បជានិច្ចផង។ *អាម៉ែន។*

**៦- ធម៌ ឱ ! ព្រះបិតាយើងខ្ញុំ**

**ច-** យើងរួមជាមួយព្រះយេស៊ូ ដែលទទួលព្រះជន្មរស់ឡើងវិញ ទូលអង្វរព្រះបិតាថា៖

**រួមគ្នា-** ឱ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !

សូមសម្តែងព្រះបារមី ឱ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ

សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់

សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ បានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ។

សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។

សូមអត់ទោសឱ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឲ្យ

អស់អ្នក ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។

សូមកុំបណ្តោយឱ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។

តែសូមរំដោះយើងខ្ញុំ ឱ្យរួចពីមារកំណាច។ *អាម៉ែន។*

**ម**- ឱ! ព្រះអម្ចាស់យើងខ្ញុំអើយ សូមទ្រង់ព្រះមេត្តាជួយយើងខ្ញុំឱ្យរួចពីអន្តរាយគ្រប់បែបយ៉ាង សូមទ្រង់ប្រោសប្រទានឱ្យយើងខ្ញុំរស់នៅបានសេចក្តីសុខសាន្ត និងរួចចាកពីអំពើបាបជានិច្ច កុំឱ្យយើងខ្ញុំជួបប្រទះនឹងទុក្ខលំបាកណាឡើយ។

យើងខ្ញុំមានសង្ឃឹមយ៉ាងមាំថា នឹងបានបរមសុខ ហើយយើងខ្ញុំក៏រង់ចាំព្រះយេស៊ូគ្រីស្ត ជាព្រះសង្គ្រោះទ្រង់យាងត្រឡប់មកវិញ។

**រួមគ្នា**- ដ្បិតព្រះអង្គគ្រងរាជ្យ ទ្រង់មានឫទ្ធានុភាព និងសិរីរុងរឿង អស់កល្បជាអង្វែងតរៀងទៅ។ *អាម៉ែន។*

**រួមគ្នា**- ឱ ! ព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំអើយ ព្រះអង្គមានព្រះបន្ទូលទៅកាន់សាវ័កទាំងឡាយថា "ខ្ញុំផ្តល់ឱ្យអ្នករាល់គ្នាបានសេចក្តីសុខសាន្ត គឺសេចក្តីសុខសាន្តរបស់ខ្ញុំ" សូមទ្រង់ព្រះមេត្តា កុំប្រកាន់ទោសរបស់យើងខ្ញុំឡើយ តែសូមទ្រង់ឈ្វេងយល់ នូវជំនឿរបស់ព្រះសហគមន៍ព្រះអង្គវិញ។ សូមទ្រង់

ប្រោសប្រទានឱ្យព្រះសហគមន៍ បានប្រកបដោយសេចក្ដីសុខសាន្ដ និងបានមូលផ្ដុំគ្នាជាធ្លុងតែមួយផង ។ព្រះអង្គទ្រង់មានព្រះជន្មគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ។ *អាម៉ែន ។*

**រួមគ្នា-** ឱ ! ព្រះយេស៊ូ ដែលរំដោះបាបមនុស្សលោកីយ៍ សូមអាណិតអាសូរយើងខ្ញុំ *(២ដង)*

ឱ ! ព្រះយេស៊ូ ដែលរំដោះបាបមនុស្សលោកីយ៍ សូមប្រទានសេចក្ដីសុខសាន្ដឱ្យយើងខ្ញុំ។

## ៧- ធម៌ បពិត្រព្រះនាងម៉ារី

**ច-** យើងពឹងលើព្រះនាងម៉ារី ជួយអង្វរព្រះអម្ចាស់ឱ្យ ....... (ឈ្មោះជាគ្រីស្ដបរិស័ទ)

**រួមគ្នា-** *បពិត្រព្រះនាងម៉ារី !*

ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់

សូមព្រះនាងមានអំណរសប្បាយ ។

ព្រះអង្គគង់ជាមួយនាង ព្រះអង្គបានប្រទានពរដល់នាង លើសស្ត្រីទាំងឡាយ ហើយទ្រង់ក៏ប្រទានពរ ដល់បុត្រព្រះនាងដែរ ។

*ឱ! សន្ដីម៉ារី ជាមាតាព្រះអម្ចាស់ !*

សូមជួយអង្វរព្រះអង្គ ឱ្យយើងខ្ញុំជាអ្នកបាប នៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង ។ *អាម៉ែន ។*

## ៨- ធម៌ សូមកោតសរសើរ

**រួមគ្នា-** សូមកោតសរសើរ

ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ

ដែលព្រះអង្គគង់នៅ តាំងពីដើមរៀងមក

ហើយជាដរាបតរៀងទៅ។ *អាម៉ែន។*

►*ធ្វើសញ្ញាឈើឆ្កាងលើថ្ងាសអ្នកជិតផុតដង្ហើមទាំងពោលថា៖*

*"សូមព្រះជាម្ចាស់ធ្វើដំណើរជាមួយ............ (ឈ្មោះជាគ្រីស្តបរិស័ទ)ផង"*

## ៩- ពាក្យអធិដ្ឋាន

ម- សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះយេស៊ូគ្រីស្ដជាអម្ចាស់ នៅពេលដែល ........... *(ឈ្មោះជាគ្រីស្តបរិស័ទ)* កំពុងរងទុក្ខលំបាកនេះ

យើងខ្ញុំសូមអង្វរព្រះអម្ចាស់ មេត្តាបំភ្លឺឲ្យគាត់មានកម្លាំង ដើម្បីរួមជាមួយទុក្ខលំបាករបស់ព្រះបុត្រាព្រះអង្គ។ សូមព្រះអង្គលើកលែងទោសរំដោះបាបដល់គាត់ ដើម្បីឱ្យគាត់អាចនៅរួមរស់ជាមួយសន្តបុគ្គលរបស់ព្រះអង្គផង។ *អាម៉ែន។*

## របៀបទី ២

►*អ្នកចូលរួមធ្វើសញ្ញាឈើឆ្កាងលើថ្ងាស ជាមួយទឹកព្រះពរ ដើម្បីរំឭកពីអគ្គសញ្ញាជ្រមុជទឹក ដែលខ្លួនបានទទួលជីវិត ទាំងផ្ញើជីវិតលើព្រះគ្រីស្តផង។*

**១- ពិធីប្រារព្ធ**

►*នៅស្ងាត់បន្តិច*

**២- ពាក្យអធិដ្ឋាន**

- ឱ! ព្រះយេស៊ូជាអម្ចាស់ ដែលព្រះបិតាបានចាត់ឱ្យយាងមកព្យាបាល និងសង្គ្រោះមនុស្សលោក សូមអាណិតអាសូរយើងខ្ញុំ។

*ឆ្លើយ* **សូមអាណិតអាសូរយើងខ្ញុំ។**

- ឱ! ព្រះគ្រីស្ត ដែលយាងមកហៅអស់អ្នកបាប សូមអាណិតអាសូរយើងខ្ញុំ។

*ឆ្លើយ* **សូមអាណិតអាសូរយើងខ្ញុំ។**

- ឱ! ព្រះយេស៊ូជាអម្ចាស់ ដែលគង់ខាងស្តាំព្រះបិតា ដើម្បីជួយអង្វរឱ្យយើងខ្ញុំ សូមអាណិតអាសូរយើងខ្ញុំ។

*ឆ្លើយ* **សូមអាណិតអាសូរយើងខ្ញុំ។**

**ច-** សូមព្រះដ៏មានតេជានុភាពសព្វប្រការ ទង់ព្រះមេត្តាលើកលែងទោសរំដោះបាបឱ្យយើងខ្ញុំ ព្រមទាំងប្រទានឱ្យយើងខ្ញុំ មានជីវិតរស់នៅអស់កល្បជានិច្ចផង។ *អាម៉ែន។*

## ទំនុកតម្កើងលេខ ១៦ (១៥) បទពាក្យ ៧

| | | | |
|---|---|---|---|
| ១- | ឱ! ព្រះជាម្ចាស់ដ៏ឧត្តម | សូមការពារខ្ញុំឱ្យសុខសាន្ត | |
| | ដ្បិតទូលបង្គំសូមផ្ញើប្រាណ | ជ្រកក្រោមទីស្ថានម្លប់បារមី | ។ |
| ២- | ខ្ញុំសូមទូលថ្វាយព្រះម្ចាស់ថា | ព្រះអង្គពិតជាអម្ចាស់ថ្លៃ | |
| | ក្រៅពីព្រះអង្គឥតមានអ្វី | ផ្តល់មង្គលជ័យគ្រាអាសន្ន | ។ |
| ៥- | បពិត្រព្រះអម្ចាស់ឧត្តម | ព្រះអង្គជាចំណែកស្រស់ស្រាយ | |
| | មត៌កនៃខ្ញុំឥតក្លែងក្លាយ | ផ្តល់អ្វីទាំងឡាយតាមប្រាថ្នា | ។ |
| ៦- | ព្រះអង្គប្រទានកេរមត៌ក | វិសេសឥតអាក់ដ៏ថ្លៃថ្លា | |
| | មកទូលបង្គំខ្ញុំនេះណា | ជាកេរអស្ចារ្យប្រសើរផុត | ។ |
| ៨- | ខ្ញុំនឹកដល់ព្រះអម្ចាស់ជាប់ | ដែលជាទម្លាប់ទ្រង់គង់ក្បែរ | |
| | ខាងស្តាំរូបខ្ញុំឥតប្រួលប្រែ | ខ្ញុំមិនបែកបែរញាប់ញ័រឡើយ | ។ |
| ១២- | ដោយព្រះអង្គគង់នៅខាងស្តាំ | ជាប់ជាប្រចាំមិនជិនណាយ | |
| | ទូលបង្គំសែនអរសប្បាយ | អស់កល្បវែងឆ្ងាយតរៀងទៅ | ។ |

## ៣- ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

### ក- ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

- *រដូវធម្មតា*

**អាលេលូយ៉ា**! សូមលើកតម្កើងព្រះយេស៊ូ ដែលទ្រង់បានឈ្នះសេចក្តីស្លាប់ ចូរយើងទទួលដោយសប្បាយ ជីវិតថ្មីពីព្រះអម្ចាស់ **អាលេលូយ៉ា**។

- *រដូវអប់រំពិសេស*

*បន្ទរ ៖* សូមលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ត ព្រះអង្គជាព្រះពន្លឺនៃព្រះជាម្ចាស់ សូមកោតសរសើរព្រះអង្គ។

ឱ! ព្រះជាម្ចាស់ សូមព្រះមេត្តា អាណិតអាសូរ កែប្រែដួងចិត្ត គំនិតយើងខ្ញុំ ដើម្បីទទួលព្រះសង្គ្រោះយើង។

**ខ- សូមថ្លែងព្រះគម្ពីរដំណឹងល្អ តែងដោយសន្តៈ ម៉ាថាយ** *(មថ ១១,២៥-២៧)*

ព្រះយេស៊ូមានព្រះបន្ទូលឡើងថា៖ "បពិត្រព្រះបិតា ជាអម្ចាស់នៃស្ថានបរមសុខ និងជាអម្ចាស់នៃផែនដី ទូលបង្គំសូមសរសើរតម្កើងព្រះអង្គ ព្រោះទ្រង់បានសម្តែងការទាំងនេះ ឱ្យមនុស្សតូចតាចយល់ តែទ្រង់បានលាក់មិនឱ្យអ្នកប្រាជ្ញ និងអ្នកចេះដឹងយល់ទេ។ មែនហើយ ! ព្រះអង្គសព្វព្រះហឫទ័យសម្រេចដូច្នេះ។

ព្រះបិតារបស់ខ្ញុំបានប្រគល់អ្វីៗទាំងអស់មកខ្ញុំ គ្មាននរណាស្គាល់ព្រះបុត្រា ក្រៅពីព្រះបិតា ហើយក៏គ្មាននរណាស្គាល់ព្រះបិតា ក្រៅពីព្រះបុត្រា និងអ្នកដែលព្រះបុត្រាសព្វព្រះហឫទ័យ សម្តែងឱ្យស្គាល់នោះដែរ"។

**ច**- នេះជាព្រះបន្ទូលដំណឹងល្អ របស់ព្រះយេស៊ូគ្រីស្តជាអម្ចាស់។

**គ**- សូមកោតសរសើរព្រះគ្រីស្តជាអម្ចាស់។

## ៤- ធម៌ ឱ ! ព្រះបិតាយើងខ្ញុំ

**ច**- យើងរួមជាមួយព្រះយេស៊ូ ដែលទទួលព្រះជន្មរស់ឡើងវិញ ទូលអង្វរព្រះបិតាថា ៖

**រួមគ្នា**- ឱ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !

សូមសម្តែងព្រះបារមី ឱ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ

សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់

សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ

បានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ។

សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។

សូមអត់ទោសឱ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោស

ឲ្យអស់អ្នក ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។

សូមកុំបណ្តោយឱ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។

តែសូមរំដោះយើងខ្ញុំ ឱ្យរួចពីមារកំណាច។ *អាម៉ែន។*

## ៥- ធម៌ បពិត្រព្រះនាងម៉ារី

**ម**- យើងពឹងលើព្រះនាងម៉ារី ជួយអង្វរព្រះអម្ចាស់ឱ្យ ....... (ឈ្មោះជាគ្រីស្ត បរិស័ទ)

**រួមគ្នា**- *បពិត្រព្រះនាងម៉ារី !*

ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់

សូមព្រះនាងមានអំណរសប្បាយ។

ព្រះអង្គគង់ជាមួយនាង ព្រះអង្គបានប្រទានពរដល់នាង លើសស្ត្រីទាំងឡាយ ហើយទ្រង់ក៏ប្រទានពរ ដល់បុត្រព្រះនាងដែរ។

*ឱ! សន្តីម៉ារី ជាមាតាព្រះអម្ចាស់ !*

សូមជួយអង្វរព្រះអង្គ ឱ្យយើងខ្ញុំជាអ្នកបាប នៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង។ *អាម៉ែន។*

## ៦- ធម៌ សូមកោតសរសើរ

**រួមគ្នា**- សូមកោតសរសើរ

ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ

ដែលព្រះអង្គគង់នៅ តាំងពីដើមរៀងមក

ហើយជាដរាបតរៀងទៅ។ *អាម៉ែន។*

## ៧- ពាក្យអធិដ្ឋាន

**ច**- សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះយេស៊ូគ្រីស្តជាអម្ចាស់ នៅពេលដែល ........... *(ឈ្មោះជាគ្រីស្តបរិស័ទ)* កំពុងរងទុក្ខលំបាកនេះ

យើងខ្ញុំសូមអង្វរព្រះអម្ចាស់ មេត្តាបំភ្លឺឲ្យគាត់មានកម្លាំង ដើម្បីរួមជាមួយទុក្ខលំបាករបស់ព្រះបុត្រាព្រះអង្គ។ សូមព្រះអង្គលើកលែងទោសរំដោះបាបដល់គាត់ ដើម្បីឱ្យគាត់អាចនៅរួមរស់ជាមួយសន្តបុគ្គលរបស់ព្រះអង្គផង។ *អាម៉ែន។*

## ២

# ពាក្យអធិដ្ឋាន
# សម្រាប់អ្នកទើបផុតដង្ហើម

• *ក្រុមគ្រួសារ និង ញាតិសាលោហិត នៅជុំវិញសព។*

### ១- ពិធីប្រារព្ធ

**ចម្រៀង "ឱ ! ព្រះបិតា សូមទទួលវិញ្ញាណក្ខ័ន្ធអ្នកបម្រើព្រះអង្គ"**

*(លំនាំបទ សូមលើកតង្វាយថ្វាយព្រះបិតា)*

១- ឱ ! ព្រះបិតា ជាព្រះជាម្ចាស់ លើសកលលោក សូមទ្រង់ទទួល
វិញ្ញាណអ្នកបម្រើ ដែលវិលទៅជួប ព្រះភ័ក្ត្រព្រះអង្គ ។

២- សូមទ្រង់មេត្តា ផ្ទៀងព្រះកាណ៌ស្ដាប់ ពាក្យកូនអង្វរ បើទ្រង់ចាប់ទោស
នោះតើមាននរណា រួចពីទោសា ស្ថិតស្ថេរនៅបាន ។

៣- យើងខ្ញុំជឿថា ទោះគាត់ប្រព្រឹត្ត ខុសឆ្គងយ៉ាងណា ក៏ទ្រង់នៅតែ
សន្ដោសប្រោសប្រណី ដល់បុត្រធីតា ព្រះអង្គដរាប *(ពីរដង)*។

**ម-** បពិតព្រះយេស៊ូគ្រីស្ដ ទ្រង់បានត្រាស់ហៅ .......... (ឈ្មោះជាគ្រីស្ដបរិស័ទ) ហើយ ! សូមទ្រង់ព្រះមេត្តាទទួលគាត់ ឱ្យនៅរួមជាមួយព្រះអង្គ ឯស្ថានបរមសុខផង។ សូមសន្ដបុគ្គលទាំងឡាយ អញ្ជើញមកទទួលបងប្អូនយើងខ្ញុំជាអ្នកបម្រើនេះ សូមនាំគាត់ឆ្ពោះទៅកាន់ព្រះភ័ក្ត្ររបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុតផង។

## ២- ពាក្យអង្វរសាកល

ង- ពេលនេះសូមបងប្អូនតាំងចិត្តអធិដ្ឋាន ទូលអង្វរព្រះអម្ចាស់ សូមព្រះអង្គពង្រឹងជំនឿរបស់យើងទាំងអស់គ្នា។ សូមទ្រង់ព្រះមេត្តាទទួលវិញ្ញាណក្ខ័ន្ធ .......... (ឈ្មោះជាគ្រីស្តបរិស័ទ) ដែលបានចែកឋានទៅហើយ សូមព្រះអង្គប្រោសប្រទានឱ្យ.................. (ឈ្មោះជាគ្រីស្តបរិស័ទ) រស់នៅរួមជាមួយព្រះអង្គអស់កល្បជានិច្ចផង។

*បន្ទរ ៖* កូនសូមស្រែកហៅ អស់ពីដួងចិត្ត សូមព្រះអម្ចាស់ ស្តាប់សម្លេងកូន។

ឌ- ១- បពិត្រព្រះបិតា ប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង ! សូមទ្រង់ព្រះមេត្តាអាណិតអាសូរ ........ (ឈ្មោះជាគ្រីស្តបរិស័ទ) ដែលបានចែកឋានទៅហើយ សូមព្រះអង្គលើកលែងទោសទាំងប៉ុន្មានរបស់គាត់ ហើយសូមទទួលគាត់នៅស្ថានបរមសុខរួមជាមួយព្រះអង្គផង។

២- បពិត្រព្រះអម្ចាស់ ជាព្រះបិតា! សូមព្រះអង្គសម្រាលទុក្ខក្រុមគ្រួសារ ញាតិសន្តានរបស់ ...... (ឈ្មោះជាគ្រីស្តបរិស័ទ)។ សូមពង្រឹងជំនឿរបស់ពួកគាត់ ឱ្យមានសេចក្តីសង្ឃឹមជានិច្ច លើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គផង។

៣- បពិត្រព្រះអម្ចាស់ជាព្រះបិតា! សូមព្រះអង្គអាណិតអាសូរដល់បងប្អូនយើងខ្ញុំ ដែលកំពុងកើតទុក្ខព្រួយនៅថ្ងៃនេះ សូមឱ្យពួកគាត់បានធូរស្បើយ សូមបំភ្លឺចិត្តគំនិតឱ្យពួកគាត់ យល់ពីទិសដៅនិងពីអត្ថន័យនៃជីវិតរបស់ខ្លួនផង។

៤- បពិត្រព្រះអម្ចាស់ជាព្រះបិតា! សូមព្រះអង្គប្រោសប្រណីដល់យើងខ្ញុំ ដែលមកជួបជុំគ្នានៅពេលនេះ។ សូមពង្រឹងជំនឿយើងខ្ញុំ ចំពោះព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ។ សូមឱ្យយើងខ្ញុំមានចិត្តសុភាពរាបសា សូមឱ្យយើងខ្ញុំជឿសង្ឃឹម និងស្រឡាញ់តាមគំរូរបស់ព្រះនាងម៉ារី និងធ្វើជីវិតទាំងស្រុងលើព្រះគ្រីស្តក្នុងគ្រប់កាលៈទេសៈផង។

**ច**- បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ ! ព្រះអង្គមានធម៌មេត្តាករុណាចំពោះមនុស្សគ្រប់ៗរូប ទ្រង់សព្វព្រះហឫទ័យមិនឱ្យនរណាម្នាក់វិនាសឡើយ។ គឺឱ្យមនុស្សទាំងអស់ ទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គនៅស្ថានបរមសុខ។ នៅពេលនេះ សូមទ្រង់ព្រះមេត្តាទទួលពាក្យអង្វររបស់យើងខ្ញុំ សូមទទួលវិញ្ញាណក្ខ័ន្ធ........ (ឈ្មោះជាគ្រីស្តបរិស័ទ) ឱ្យរស់នៅរួមជាមួយព្រះអង្គ និងសូមព្រឹងងជំនឿយើងខ្ញុំផង។

យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

### **ទំនុកតម្កើងលេខ ២៧** (**២៦**)

- ព្រះអម្ចាស់ទ្រង់ជាពន្លឺ នាមល្បីរន្ទឺព្រះសង្គ្រោះ
  មិនឱ្យខ្ញុំខ្លាចនរណាសោះ ជាកំពែងខ្ពស់ជួយជីវិត ។

- ខ្ញុំទូលព្រះម្ចាស់នូវសេចក្តី តែមួយគត់ខ្លីឱ្យបានច្បាស់
  គឺចង់ស្នាក់នៅដំណាក់ព្រះ ឥតមានក្រឡះមួយជីវិត ។

- ដើម្បីខ្ញុំបានកោតស្ញែងស្ញប់ ឫទ្ធានុភាពថ្កុំថ្កើងពិត
  និងថ្វាយបង្គំម្ចាស់ជីវិត ព្រះអង្គគង់ស្ថិតក្នុងវិហារ ។

- ខ្ញុំជឿជាក់ថាខ្ញុំនឹងបាន ឃើញមុខក្សេមក្សាន្តមិនអាស្រូវ
  មង្គលកើតពីព្រះម្ចាស់នៅ ក្នុងលោកតទៅជាមិនខាន ។

- ចូរទុកចិត្តលើព្រះអម្ចាស់ ព្រះអង្គជាព្រះដ៏ថ្កើងថ្កាន
  ចូរមានកម្លាំងចិត្តក្លាហាន នោះអ្នកនឹងមានសុភមង្គល ។

**៣- ធម៌ ឱ ! ព្រះបិតាយើងខ្ញុំ**

**ម-** យើងរួមជាមួយព្រះយេស៊ូ ដែលទទួលព្រះជន្មរស់ឡើងវិញ ទូលអង្វរព្រះបិតាថា៖

**រួមគ្នា-** ឱ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !
សូមសម្ដែងព្រះបារមី ឱ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ
សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់
សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ
បានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ។

សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។
សូមអត់ទោសឱ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោស
ឲ្យអស់អ្នក ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។
សូមកុំបណ្ដោយឱ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។
តែសូមរំដោះយើងខ្ញុំ ឱ្យរួចពីមារកំណាច។ *អាម៉ែន។*

**៥- ធម៌ បពិត្រព្រះនាងម៉ារី**

**ម-** យើងពឹងលើព្រះនាងម៉ារី ជួយអង្វរព្រះអម្ចាស់ឱ្យ ....... (ឈ្មោះជាគ្រីស្តបរិស័ទ)

**រួមគ្នា-** *បពិត្រព្រះនាងម៉ារី !*
ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់
សូមព្រះនាងមានអំណរសប្បាយ។
ព្រះអង្គគង់ជាមួយនាង ព្រះអង្គបានប្រទានពរដល់នាង លើសស្ត្រីទាំងឡាយ

ហើយទ្រង់ក៏ប្រទានពរ ដល់បុត្រព្រះនាងដែរ។

*ឱ! សន្ដីម៉ារី ជាមាតាព្រះអម្ចាស់ !*

សូមជួយអង្វរព្រះអង្គ ឱ្យយើងខ្ញុំជាអ្នកបាប នៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង។ *អាម៉ែន។*

## ៦- ពាក្យអង្វរ

បពិត្រព្រះបិតាជាអម្ចាស់ ! យើងខ្ញុំសូមអង្វរព្រះអង្គ សូមទ្រង់ព្រះមេត្តាទទួលវិញ្ញាណក្ខ័ន្ធអ្នកបម្រើព្រះអង្គ ដែលទើបនឹងចែកស្ថានអម្បាញ់មិញនេះ។ សូមប្រោសប្រទាន ឱ្យអ្នកបម្រើនេះ បានពោរពេញដោយអំណរសប្បាយនៅស្ថានបរមសុខរួមជាមួយព្រះអង្គផង។ ទោះបីគាត់បានប្រព្រឹត្តអំពើបាបយ៉ាងណាក៏ដោយ ក៏សូមព្រះអង្គទ្រង់ព្រះមេត្តាលើកលែងទាសឱ្យគាត់ ដោយព្រះហឫទ័យមេត្តាករុណាដ៏លើសលប់របស់ព្រះអង្គ។

យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ដ និងជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

# ៣ ពិធីអធិដ្ឋាន សម្រាប់វិញ្ញាណក្ខ័ន្ធអ្នកស្លាប់

(សូមប្រើរបៀប ១ ឬ ២)

*របៀបទី១*

**១- ពិធីប្រារព្ធ**

► *សូមតម្កល់រូបថតនៅខាងចុងជើងសព។*

► *អញ្ជើញញាតិមិត្តមកអុជធូប នៅមុខសព ជាកិច្ចគោរពវិញ្ញាណក្ខ័ន្ធសព។*

► *គ្រីស្តបរិស័ទស្មូតទំនុកតម្កើង ឬច្រៀង។*

**ច-** ក្នុងព្រះនាមព្រះពិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ *អាម៉ែន។*

យើងបានដុតធូបទុកជាកិច្ចគោរពសព......... (ឈ្មោះជាគ្រីស្តបរិស័ទ) ដែលបានចែកឋានទៅហើយ។ សូមបងប្អូនរួមគ្នាអង្វរព្រះជាម្ចាស់ សូមព្រះអង្គទទួលវិញ្ញាណក្ខ័ន្ធ .................... (ឈ្មោះជាគ្រីស្តបរិស័ទ) ដែលដូចផ្សែងធូបកំពុងហុយឡើងទៅលើនៅពេលនេះដែរ។ សូមព្រះជាម្ចាស់ទ្រង់ព្រះមេត្តាលើកលែងទោសឱ្យ ............... (ឈ្មោះជាគ្រីស្តបរិស័ទ) ផង។

**ទំនុកតម្កើងលេខ ៥១ (៥០) បទ ភាគគតិ**

- ឱ! ព្រះអម្ចាស់ ប្រសើរពេកណាស់ ដោយធម៌មេត្តា សូមទ្រង់អាណិត
  លើកលែងទោសា ឱ្យខ្ញុំផងណា ដោយអនុគ្រោះ ។

- សូមទ្រង់ឧបត្ថម្ភ ចិត្តគំនិតខ្ញុំ ឱ្យបានខ្ពង់ខ្ពស់ ឱ្យបានបរិសុទ្ធ
  ផុតចាកបាបគ្រោះ រួចពីទុក្ខទោស សព្វគ្រប់ប្រការ ។

- ខ្ញុំសូមសារភាព នូវអំពើបាប តូចធំយ៉ាងណា ហើយតែងនឹកចាំ
  រាល់ទិនទិវា បាបគ្រប់ប្រការ ដែលខ្ញុំប្រព្រឹត្ត ។

- ទាំងការអាក្រក់ អំពើលាមក ឬក្តីទុច្ចរិត ដែលខ្ញុំបានធ្វើ
  និងបានប្រព្រឹត្ត ជាកំហុសពិត ចំពោះព្រះភក្ត្រ ។

- ទ្រង់វិនិច្ឆ័យ ព្រមទាំងកាត់ក្តី ដោយធម៌សច្ចៈ ចំពោះបាបកម្ម
  ដែលខ្ញុំជំពាក់ ពីអតីតៈ ដោយយុត្តិធម៌ ។

- ទ្រង់សព្វហឫទ័យ នឹងជនប្រុសស្រី មានចិត្តស្មោះស សូមទ្រង់ទូន្មាន
  នូវសច្ចធម៌ ឱ្យស្គាល់ផ្លូវល្អ នៅក្នុងលោកីយ៍ ។

- សូមទ្រង់កម្ចាត់ ព្រមទាំងបំបាត់ អំពើអប្រីយ៍ សូមឱ្យរូបខ្ញុំ
  ប្រាសចាកទុក្ខភ័យ អស់គ្រោះចង្រៃ ស្គាល់ក្តីភិរម្យ ។

- សូមទ្រង់មេត្តា លើកលែងទោសា របស់រូបខ្ញុំ សូមទ្រង់រំដោះ
  ឱ្យបានសុខុម ហើយសូមទ្រង់កុំ បោះបង់ចោលខ្ញុំ ។

- ឱ! ព្រះជាម្ចាស់ សូមទ្រង់ជម្រះ ចិត្តគំនិតខ្ញុំ ឱ្យស្អាតបរិសុទ្ធ
  ម៉ត់ចត់សុខុម អង់អាចឧត្តម មាំមួនដរាប ។

- សូមព្រះអង្គកុំ បោះបង់រូបខ្ញុំ ជាជនទទន់ទាប ឱ្យឃ្លាតចេញឆ្ងាយ
  ដូចអ្នកមានបាប សូមរស់ដរាប ក្បែរព្រះឧត្តម ។

| | | | |
|---|---|---|---|
| - ឯព្រះវិញ្ញាណ | វិសុទ្ធថ្កើងថ្កាន | ថ្លៃថ្លាឧត្តម | សូមទ្រង់មេត្តា |
| កុំចាកចោលខ្ញុំ | ឱ្យនៅក្រៀមក្រំ | តែឯងឯកា | ។ |
| - សូមទ្រង់ប្រទាន | ឱ្យរូបខ្ញុំមាន | សទ្ធាជ្រះថ្លា | ឱ្យបានសប្បាយ |
| រីករាយចិន្តា | ដោយទ្រង់មេត្តា | សង្គ្រោះគាំទ្រ | ។ |
| - សូមថ្លែងជោគជ័យ | ដ៏អស្ចារ្យក្រៃ | នៃព្រះបិតា | សូមកោតបារមី |
| នៃព្រះបុត្រា | សូមកោតចេស្តា | នៃព្រះវិញ្ញាណ | ។ |

## ២- ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

### ក- លិខិតទី១ របស់គ្រីស្តទូតប៉ូល ផ្ញើជូនគ្រីស្តបរិស័ទក្រុងថេស្សាឡូនិក

*( ថស ៤,១៣-១៤, ១៧-១៨ )*

បងប្អូនអើយ! យើងចង់ឱ្យបងប្អូនជ្រាបយ៉ាងច្បាស់ អំពីអស់អ្នកដែលបានស្លាប់ផុតទៅហើយ ដើម្បីកុំឱ្យបងប្អូនព្រួយចិត្ត ដូចអ្នកឯទៀតៗ ដែលគ្មានសេចក្តីសង្ឃឹមនោះឡើយ។ ប្រសិនបើយើងជឿថា ព្រះយេស៊ូពិតជាបានសោយទិវង្គត ហើយមានព្រះជន្មរស់ឡើងវិញមែន យើងក៏ជឿថា ព្រះជាម្ចាស់នឹងនាំបងប្អូនដែលបានស្លាប់ទៅហើយ ឱ្យទៅនៅជាមួយព្រះអង្គ ដោយសារព្រះយេស៊ូដែរ។ ព្រះអម្ចាស់លើកយើងដែលនៅរស់នៅឡើយ ឱ្យឡើងទៅក្នុងពពកជាមួយបងប្អូនទាំងនោះ ដើម្បីជួបនឹងព្រះអង្គក្នុងអាកាសវេហាស៍ ហើយយើងនឹងស្ថិតនៅជាមួយព្រះអម្ចាស់រហូតតទៅ។ ដូច្នេះសូមបងប្អូនយកពាក្យទាំងនេះ មកសម្រាលទុក្ខគ្នាទៅវិញទៅមក។

**ប**- នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។

**គ**- សូមអរព្រះគុណព្រះអង្គ។

►*នៅស្ងៀមស្ងាត់*

## ៣- ពាក្យអង្វរសាកល

ម- ពេលនេះសូមបងប្អូនតាំងចិត្តអធិដ្ឋាន ទូលអង្វរព្រះអម្ចាស់ សូមព្រះអង្គពង្រឹងជំនឿរបស់យើងទាំងអស់គ្នា។ សូមទ្រង់ព្រះមេត្តាទទួលវិញ្ញាណក្ខ័ន្ធ ..........(ឈ្មោះជាគ្រីស្តបរិស័ទ) ដែលបានចែកឋានទៅហើយ សូមព្រះអង្គប្រោសប្រទានឱ្យ.................. (ឈ្មោះជាគ្រីស្តបរិស័ទ) រស់នៅរួមជាមួយព្រះអង្គអស់កល្បជានិច្ចផង។

*បន្ទរ ៖* កូនសូមស្រែកហៅ អស់ពីដួងចិត្ត សូមព្រះអម្ចាស់ ស្តាប់សម្លេងកូន។

គ- ១- បពិត្រព្រះបិតា ប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង ! សូមទ្រង់ព្រះមេត្តាអាណិតអាសូរ ........ (ឈ្មោះជាគ្រីស្តបរិស័ទ) ដែលបានចែកឋានទៅហើយ សូមព្រះអង្គលើកលែងទោសទាំងប៉ុន្មានរបស់គាត់ ហើយសូមទទួលគាត់នៅស្ថានបរមសុខរួមជាមួយព្រះអង្គផង។

២- បពិត្រព្រះអម្ចាស់ ជាព្រះបិតា! សូមព្រះអង្គសម្រាលទុក្ខក្រុមគ្រួសារ ញាតិសន្តានរបស់ ...... (ឈ្មោះជាគ្រីស្តបរិស័ទ)។ សូមពង្រឹងជំនឿរបស់ពួកគាត់ ឱ្យមានសេចក្តីសង្ឃឹមជានិច្ច លើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គផង។

៣- បពិត្រព្រះអម្ចាស់ជាព្រះបិតា! សូមព្រះអង្គអាណិតអាសូរដល់បងប្អូនយើងខ្ញុំ ដែលកំពុងកើតទុក្ខព្រួយនៅថ្ងៃនេះ សូមឱ្យពួកគាត់បានធូរស្បើយ សូមបំភ្លឺចិត្តគំនិតឱ្យពួកគាត់ យល់ពីទិសដៅនិងពីអត្ថន័យនៃជីវិតរបស់ខ្លួនផង។

៤- បពិត្រព្រះអម្ចាស់ជាព្រះបិតា! សូមព្រះអង្គប្រោសប្រណីដល់យើងខ្ញុំ ដែលមកជួបជុំគ្នានៅពេលនេះ។ សូមពង្រឹងជំនឿយើងខ្ញុំ ចំពោះព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ។ សូមឱ្យយើងខ្ញុំមានចិត្តសុភាពរាបសា សូមឱ្យយើងខ្ញុំជឿសង្ឃឹម និងស្រឡាញ់តាមគំរូរបស់ព្រះនាងម៉ារី និងធ្វើជីវិតទាំងស្រុងលើព្រះគ្រីស្តក្នុងគ្រប់កាលៈទេសៈផង។

**ច**- បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ ! ព្រះអង្គមានធម៌មេត្តាករុណាចំពោះមនុស្សគ្រប់ៗរូប ទ្រង់សព្វព្រះហឫទ័យមិនឱ្យនរណាម្នាក់វិនាសឡើយ។ គឺឱ្យមនុស្សទាំងអស់ ទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គនៅស្ថានបរមសុខ។ នៅពេលនេះ សូមទ្រង់ព្រះមេត្តាទទួលពាក្យអង្វររបស់យើងខ្ញុំ សូមទទួលវិញ្ញាណក្ខ័ន្ធ........ (ឈ្មោះជាគ្រីស្តបរិស័ទ) ឱ្យរស់នៅរួមជាមួយព្រះអង្គ និងសូមព្រឹងងជំនឿយើងខ្ញុំផង។

យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

### ៤- ធម៌ ឱ ! ព្រះបិតាយើងខ្ញុំ

**ច**- យើងរួមជាមួយព្រះយេស៊ូ ដែលទទួលព្រះជន្មរស់ឡើងវិញ ទូលអង្វរព្រះបិតាថា៖

**រួមគ្នា**- ឱ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !
សូមសម្តែងព្រះបារមី ឱ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ
សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់
សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ
បានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ។

សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។
សូមអត់ទោសឱ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោស
ឲ្យអស់អ្នក ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។
សូមកុំបណ្តោយឱ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។
តែសូមរំដោះយើងខ្ញុំ ឱ្យរួចពីមារកំណាច។ *អាម៉ែន។*

## ៥- ធម៌ បពិត្រព្រះនាងម៉ារី

**ច-** យើងពឹងលើព្រះនាងម៉ារី ជួយអង្វរព្រះអម្ចាស់ឱ្យ ....... (ឈ្មោះជាគ្រីស្ត បរិស័ទ)

**រួមគ្នា-** *បពិត្រព្រះនាងម៉ារី !*

ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់

សូមព្រះនាងមានអំណរសប្បាយ។

ព្រះអង្គគង់ជាមួយនាង ព្រះអង្គបានប្រទានពរដល់នាង លើសស្ត្រីទាំងឡាយ ហើយទ្រង់ក៏ប្រទានពរ ដល់បុត្រព្រះនាងដែរ។

*ឱ! សន្តីម៉ារី ជាមាតាព្រះអម្ចាស់ !*

សូមជួយអង្វរព្រះអង្គ ឱ្យយើងខ្ញុំជាអ្នកបាប នៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង។ *អាម៉ែន។*

## ៦- ធម៌ សូមកោតសរសើរ

**រួមគ្នា-** សូមកោតសរសើរ

ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ

ដែលព្រះអង្គគង់នៅ តាំងពីដើមរៀងមក

ហើយជាដរាបតរៀងទៅ។ *អាម៉ែន។*

## របៀបទី២

### ១- ពិធីប្រារព្ធ

**ទំនុកតម្កើងលេខ ១៣០ ( ១២៩ )  បទ ភាគគតិ**

- កូនដង្ហោយហៅ  ពីទីជម្រៅ  រកព្រះបវរ  សូមព្រះសណ្ដាប់
  ពាក្យកូនអង្វរ  និងសូមថ្វាយពរ  ឆ្ពោះម្ចាស់សួគ៌ា  ។
- ឱ ! ព្រះសង្គ្រោះ  សូមជួយសន្ដោស  មនុស្សលោកា  កុំចាប់កំហុស
  តើមាននរណា  រួចពីទោសា  ស្ថិតស្ថេរនៅបាន  ។
- ចំណែកព្រះអង្គ  តែងជួយស្រោចស្រង់  លើកលែងទោសបាន  យើងគួរកោតខ្លាច
  ព្រះម្ចាស់ថ្កើងថ្កាន  ដោយចិត្តក្លាហាន  បង្គំបូជា  ។
- កូនជឿសង្ឃឹម  ត្រេកអរញញឹម  អស់ពីចិន្ដា  គោរពព្រះអង្គ
  កោតខ្លាចចេស្ដា  ពឹងព្រះអង្គា  ខ្ពង់ខ្ពស់ថ្លាថ្លៃ  ។
- ឱ្យ! ព្រលឹងខ្ញុំ  ចាំព្រះឧត្ដម  ទាំងយប់ទាំងថ្ងៃ  ជាងអ្នកឃ្លាំចាំ
  មើលបច្ចូសសម័យ  ចាំពន្លឺថ្ងៃ  ពេលព្រឹកព្រលឹម  ។
- ឱ ! ព្រះជាម្ចាស់  ខ្ពង់ខ្ពស់ពេកណាស់  គ្មានអ្វីប្រៀបផ្ទឹម  កូនចៅព្រះអង្គ
  ត្រេកអរញញឹម  មានចិត្តសង្ឃឹម  លើព្រះប្រោសលោះ ។
- ដោយសារព្រះអង្គ  មកជួយស្រោចស្រង់  ដោយអនុគ្រោះ  កូនចៅព្រះអង្គ
  ឱ្យផុតបាបគ្រោះ  ទ្រង់ជួយរំដោះ  ចាកផុតទោសា  ។
- សូមថ្លែងជោគជ័យ  ប្រសើរថ្លាថ្លៃ  អស់ពីចិន្ដា  ថ្លែងអំណរគុណ
  ឆ្ពោះព្រះបិតា  ទាំងព្រះបុត្រា  និងព្រះវិញ្ញាណ  ។

## **២- ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់**

### **ក- ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

● *រដូវធម្មតា*

**អាលេលូយ៉ា** ! សូមលើកតម្កើងព្រះយេស៊ូ ដែលទ្រង់បានឈ្នះសេចក្ដីស្លាប់ ចូរយើងទទួលដោយសប្បាយ ជីវិតថ្មីពីព្រះអម្ចាស់ **អាលេលូយ៉ា**។

● *រដូវអប់រំពិសេស*

*បន្ទរ ៖* សូមលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ត ព្រះអង្គជាព្រះពន្លឺ នៃព្រះជាម្ចាស់ សូមកោតសរសើរព្រះអង្គ។

ឱ! ព្រះជាម្ចាស់ សូមព្រះមេត្តា អាណិតអាសូរ កែប្រែដួងចិត្ត គំនិតយើងខ្ញុំ ដើម្បីទទួលព្រះសង្គ្រោះយើង។

### **ខ- សូមថ្លែងព្រះគម្ពីរដំណឹងល្អ តាមសន្តៈ យ៉ូហាន** *(យហ ១១, ១៧-២៧)*

កាលព្រះយេស៊ូយាងទៅដល់ផ្ទះនាងម៉ារី និងនាងម៉ាថា ព្រះអង្គក៏ជ្រាបថា គេបានដាក់សពលោកឡាសារក្នុងផ្នូរ បួនថ្ងៃហើយ។ ភូមិបេថានី មានចម្ងាយប្រមាណបីគីឡូម៉ែត្រ។ មានជនជាតិយូដាជាច្រើន នាំគ្នាមកជួយរំលែកទុក្ខនាងម៉ាថា និងនាងម៉ារី ក្នុងពេលប្អូនស្លាប់។ កាលនាងម៉ាថាបានដឹងថា ព្រះយេស៊ូយាងមកដល់ នាងក៏ចេញទៅទទួលព្រះអង្គ រីឯនាងម៉ារីវិញ នាងអង្គុយនៅក្នុងផ្ទះ។នាងម៉ាថាទូលព្រះយេស៊ូថា៖ "លោកម្ចាស់ ប្រសិនបើលោកបាននៅទីនេះ ប្អូននាងខ្ញុំមិនស្លាប់ទេ។ ប៉ុន្តែឥឡូវនេះនាងខ្ញុំដឹងថា បើលោកសុំអ្វីពីព្រះជាម្ចាស់ក៏ដោយ ព្រះអង្គមុខជាប្រទានឱ្យមិនខាន"។ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ "ប្អូននាងនឹងរស់ឡើងវិញ"។ នាងទូលទៅព្រះអង្គវិញថា៖ "នាងខ្ញុំដឹងហើយនៅថ្ងៃចុងក្រោយបំផុត កាលណាមនុស្សស្លាប់នឹងរស់ឡើងវិញ ប្អូននាងខ្ញុំក៏នឹងរស់ឡើងវិញដែរ"។ ព្រះយេស៊ូមានព្រះបន្ទូលទៅ

នាងថា៖ "ខ្ញុំហ្នឹងហើយ ដែលប្រោសមនុស្សឱ្យរស់ឡើងវិញ ខ្ញុំនឹងផ្ដល់ឱ្យគេមានជីវិត។ អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន។ រីឯអស់អ្នកដែលកំពុងតែមានជីវិតនៅរស់ ហើយជឿលើខ្ញុំ មិនស្លាប់សោះឡើយ តើនាងជឿសេចក្ដីនេះឬទេ?"។ នាងម៉ាថាទូលព្រះអង្គថា៖ "បពិត្រព្រះអម្ចាស់ ! ខ្ញុំម្ចាស់ជឿថា ព្រះអង្គពិតជាព្រះគ្រីស្ដ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយពិតជាព្រះអង្គដែលត្រូវយាងមកក្នុងពិភពលោកនេះមែន!"។

**ម**- នេះជាព្រះបន្ទូលដំណឹងល្អ របស់ព្រះយេស៊ូគ្រីស្ដជាអម្ចាស់ !

**គ**- សូមកោតសរសើរព្រះគ្រីស្ដ។

## ៣- ពាក្យអង្វរសាកល

**ម**- ពេលនេះសូមបងប្អូនតាំងចិត្តអធិដ្ឋាន ទូលអង្វរព្រះអម្ចាស់ សូមព្រះអង្គពង្រឹងជំនឿរបស់យើងទាំងអស់គ្នា។ សូមទ្រង់ព្រះមេត្តាទទួលវិញ្ញាណក្ខ័ន្ធ .......... (ឈ្មោះជាគ្រីស្ដបរិស័ទ) ដែលបានចែកឋានទៅហើយ សូមព្រះអង្គប្រោសប្រទានឱ្យ.................. (ឈ្មោះជាគ្រីស្ដបរិស័ទ) រស់នៅរួមជាមួយព្រះអង្គអស់កល្បជានិច្ចផង។

*បន្ទរ ៖* កូនសូមស្រែកហៅ អស់ពីដួងចិត្ត សូមព្រះអម្ចាស់ ស្ដាប់សម្លេងកូន។

**គ**- ១- បពិត្រព្រះបិតា ប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង ! សូមទ្រង់ព្រះមេត្តាអាណិតអាសូរ ........ (ឈ្មោះជាគ្រីស្ដបរិស័ទ) ដែលបានចែកឋានទៅហើយ សូមព្រះអង្គលើកលែងទោសទាំងប៉ុន្មានរបស់គាត់ ហើយសូមទទួលគាត់នៅស្ថានបរមសុខរួមជាមួយព្រះអង្គផង។

២- បពិត្រព្រះអម្ចាស់ ជាព្រះបិតា! សូមព្រះអង្គសម្រាលទុក្ខក្រុមគ្រួសារ ញាតិសន្ដានរបស់ ...... (ឈ្មោះជាគ្រីស្ដបរិស័ទ)។ សូមពង្រឹងជំនឿរបស់ពួកគាត់ ឱ្យមានសេចក្ដីសង្ឃឹមជានិច្ច លើព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គផង។

៣- បពិត្រព្រះអម្ចាស់ជាព្រះបិតា! សូមព្រះអង្គអាណិតអាសូរដល់បងប្អូនយើងខ្ញុំ ដែលកំពុងកើតទុក្ខព្រួយនៅថ្ងៃនេះ សូមឱ្យពួកគាត់បានធូរស្បើយ សូមបំភ្លឺចិត្តគំនិតឱ្យពួកគាត់ យល់ពីទិសដៅនិងពីអត្ថន័យនៃជីវិតរបស់ខ្លួនផង។

៤- បពិត្រព្រះអម្ចាស់ជាព្រះបិតា! សូមព្រះអង្គប្រោសប្រណីដល់យើងខ្ញុំ ដែលមកជួបជុំគ្នានៅពេលនេះ។ សូមពង្រឹងជំនឿយើងខ្ញុំ ចំពោះព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ។ សូមឱ្យយើងខ្ញុំមានចិត្តសុភាពរាបសា សូមឱ្យយើងខ្ញុំជឿសង្ឃឹម និងស្រឡាញ់តាមគំរូរបស់ព្រះនាងម៉ារី និងធ្វើជីវិតទាំងស្រុងលើព្រះគ្រីស្តក្នុងគ្រប់កាលៈទេសៈផង។

**ច-** បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ ! ព្រះអង្គមានធម៌មេត្តាករុណាចំពោះមនុស្សគ្រប់ៗរូប ទ្រង់សព្វព្រះហឫទ័យមិនឱ្យនរណាម្នាក់វិនាសឡើយ។ គឺឱ្យមនុស្សទាំងអស់ ទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គនៅស្ថានបរមសុខ។ នៅពេលនេះ សូមទ្រង់ព្រះមេត្តាទទួលពាក្យអង្វររបស់យើងខ្ញុំ សូមទទួលវិញ្ញាណក្ខ័ន្ធ........ (ឈ្មោះជាគ្រីស្តបរិស័ទ) ឱ្យរស់នៅរួមជាមួយព្រះអង្គ និងសូមព្រឹងងជំនឿយើងខ្ញុំផង។

យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

## ៤- ធម៌ ឱ ! ព្រះបិតាយើងខ្ញុំ

**ច-** យើងរួមជាមួយព្រះយេស៊ូ ដែលទទួលព្រះជន្មរស់ឡើងវិញ ទូលអង្វរព្រះបិតាថា៖

**រួមគ្នា-** ឱ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !

សូមសម្ដែងព្រះបារមី ឱ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ

សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់

សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ

បានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ។

សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។

សូមអត់ទោសឱ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោស

ឲ្យអស់អ្នក ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។

សូមកុំបណ្ដោយឱ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។

តែសូមរំដោះយើងខ្ញុំ ឱ្យរួចពីមារកំណាច។ *អាម៉ែន។*

## ៥- ធម៌ បពិត្រព្រះនាងម៉ារី

**ច-** យើងពឹងលើព្រះនាងម៉ារី ជួយអង្វរព្រះអម្ចាស់ឱ្យ ....... (ឈ្មោះជាគ្រីស្តបរិស័ទ)

**រួមគ្នា-** *បពិត្រព្រះនាងម៉ារី !*

ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់

សូមព្រះនាងមានអំណរសប្បាយ។

ព្រះអង្គគង់ជាមួយនាង ព្រះអង្គបានប្រទានពរដល់នាង លើសស្ត្រីទាំងឡាយ ហើយទ្រង់ក៏ប្រទានពរ ដល់បុត្រព្រះនាងដែរ។

*ឱ! សន្តីម៉ារី ជាមាតាព្រះអម្ចាស់ !*

សូមជួយអង្វរព្រះអង្គ ឱ្យយើងខ្ញុំជាអ្នកបាប នៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង។ *អាម៉ែន។*

## ៦- ពាក្យបញ្ចប់

**ប**- ឱ ! ព្រះអម្ចាស់អើយ ! ដោយព្រះយេស៊ូ ជាព្រះបុត្រាព្រះអង្គ កើតជាមនុស្ស។

**គ** - *សូមអាណិតអាសូរ ... (ឈ្មោះជាគ្រីស្តបរិស័ទ) ផង។*

**ប**- ឱ ! ព្រះអម្ចាស់អើយ ! ដោយព្រះបុត្រាស្រឡាញ់យើងខ្ញុំ រហូតដល់បូជាព្រះជន្ម លើឈើឆ្កាង។

**គ** - *សូមអាណិតអាសូរ ... (ឈ្មោះជាគ្រីស្តបរិស័ទ) ផង។*

**ប**- ឱ ! ព្រះអម្ចាស់អើយ ! ដោយព្រះបុត្រាមានព្រះជន្មរស់ឡើងវិញ ព្រះបុត្រាចម្លងយើងខ្ញុំ ទៅកាន់ព្រះបិតា និងប្រទានឱ្យមនុស្សលោក មានជីវិតដ៏ពេញលេញ។

**គ** - *សូមអាណិតអាសូរ ... (ឈ្មោះជាគ្រីស្តបរិស័ទ) ផង។*

**ប**- ឱ ! ព្រះអម្ចាស់អើយ ! ព្រះវិញ្ញាណដែលព្រះអង្គប្រទានមកយើងខ្ញុំ បញ្ជាក់ថា ព្រះអង្គស្រឡាញ់យើងខ្ញុំ។

**គ** - *សូមអាណិតអាសូរ ... (ឈ្មោះជាគ្រីស្តបរិស័ទ) ផង។*

**ប**- បពិត្រព្រះជាម្ចាស់ ! ព្រះអង្គពិតជាព្រះបិតា ប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង។ សូមទ្រង់ព្រះមេត្តាអាណិតអាសូរ...... (ឈ្មោះជាគ្រីស្តបរិស័ទ) ដែលចែកស្ថានទៅហើយ និងសូមប្រោសប្រទានឱ្យគាត់បានសេចក្តីសុខសាន្ត និងបានអំណរសប្បាយដ៏ពេញលេញរួមជាមួយ អស់អ្នកដែលចូលក្នុងព្រះរាជ្យព្រះអង្គផង។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

## ៤ ពិធីដាក់សព ក្នុងមឈូស

### ១- ពិធីប្រារព្ធ

- *ពាក្យស្វាគមន៍ និង ដាស់តឿនគ្រីស្តបរិស័ទ។*

ច- ពេលនេះយើងជាគ្រីស្តបរិស័ទ និងជាញាតិមិត្តបានរួមគ្នានៅទីនេះ ដើម្បីរំលែកទុក្ខក្រុមគ្រួសារ សាច់សាលោហិតរបស់....... (ឈ្មោះជាគ្រីស្តបរិស័ទ)។

សូមព្រះជាម្ចាស់សម្រាលទុក្ខក្រុមគ្រួសារទាំងមូល និងសូមព្រះអង្គពង្រឹងជំនឿរបស់ពួកគាត់ នៅក្នុងថ្ងៃដ៏សែនទុក្ខព្រួយនេះផង។ យើងខ្ញុំទាំងអស់គ្នា សូមទូលអង្វរព្រះអង្គ សូមព្រះមេត្តាទទួលវិញ្ញាណក្ខ័ន្ធ ..... (ឈ្មោះជាគ្រីស្តបរិស័ទ) ឱ្យនៅរួមជាមួយព្រះអង្គ នៅស្ថានបរមសុខ តាមព្រះបន្ទូលសន្យារបស់ព្រះអង្គ។ យើងខ្ញុំសូមដុតធូបទុកជាសញ្ញាសម្គាល់បញ្ជាក់ជំនឿរបស់យើងថា មនុស្សស្លាប់នឹងមានជីវិតរួមជាមួយព្រះគ្រីស្តអស់កល្បជានិច្ច។

►*អញ្ជើញក្រុមគ្រួសារ ញាតិសាលោហិត ដុតទៀន ឬ ធូប*

►*ក្នុងពេលនោះច្រៀងបទ ៖ "ចូរយើងផ្ទង់ស្មារតីនឹក"*

*បន្ទរ ៖* ចូរយើងទាំងអស់ផ្ទង់ស្មារតីនឹក កុំបីភ្លេចភ្លឹកអំពីព្រះជន្ម
នៃព្រះយេស៊ូដែលបានរស់រាន ដោយព្រះវិញ្ញាណវិសេសវិសុទ្ធ។

១- ប្រសិនបើយើងស្លាប់ ដោយមានភ័ព្វរួមព្រះគ្រីស្ត មុខជាមានជីវិតអើយ
រួមជាមួយព្រះអង្គដែរ ។

| | | |
|---|---|---|
| ២- ប្រសិនបើយើងទ្រាំ | រងទុក្ខលំបាកឥតល្ហែ | យើងមុខជាបានក្បែរអើយ |
| | សោយរាជ្យរួមនឹងព្រះអង្គ | ។ |
| ៣- ប្រសិនយើងវៀចវេរ | ចិត្តវេរាមិនស្មោះត្រង់ | ព្រះអង្គមិនបោះបង់អើយ |
| | នៅតែមានហឫទ័យស្ម័គ្រ | ។ |

## ២- ពាក្យអធិដ្ឋាន

បពិត្រព្រះអម្ចាស់ជាព្រះបិតា ! យើងខ្ញុំសូមប្រគល់ ...... ( ឈ្មោះជាគ្រីស្តបរិស័ទ ) ដែលបានធ្វើដំណើរទៅឯព្រះអង្គដោយចិត្តសង្ឃឹមថា អស់អ្នកដែលសង្ឃឹមលើព្រះគ្រីស្ត នឹងសម្រាកយ៉ាងសុខសាន្ត ព្រមទាំងមានជីវិតរួមជាមួយព្រះអង្គផង។ សូមទ្រង់ព្រះមេត្តាពង្រឹងជំនឿយើងខ្ញុំ និងប្រោសយើងខ្ញុំឱ្យបានរួមរស់ជាមួយ ....... ( ឈ្មោះជាគ្រីស្តបរិស័ទ ) នៅថ្ងៃណាមួយរួមជាមួយព្រះអង្គផង។

យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត ជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

## ៣- ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

### ក- លិខិតទី១ របស់គ្រីស្តទូតប៉ូលផ្ញើជូនគ្រីស្តបរិស័ទក្រុងថេស្សាឡូនិក

*( ថស ៤,១៣-១៤, ១៧-១៨ )*

បងប្អូនអើយ ! យើងចង់ឱ្យបងប្អូនជ្រាបយ៉ាងច្បាស់ អំពីអស់អ្នកដែលបានស្លាប់ផុតទៅហើយ ដើម្បីកុំឱ្យបងប្អូនព្រួយចិត្តដូចអ្នកឯទៀតៗ ដែលគ្មានសេចក្តីសង្ឃឹមនោះឡើយ ប្រសិនបើយើងជឿថា ព្រះយេស៊ូពិតជាបានសោយទិវង្គត ហើយមានព្រះជន្មរស់ឡើងវិញមែន យើងក៏ជឿថា ព្រះជាម្ចាស់នឹងនាំបងប្អូនដែលបានស្លាប់ទៅហើយ ឱ្យទៅនៅជាមួយព្រះអង្គដោយសារព្រះយេស៊ូដែរ។ ព្រះអម្ចាស់លើកយើងដែលនៅរស់នៅឡើយ ឱ្យឡើងទៅក្នុងពពកជាមួយបងប្អូនទាំងនោះ ដើម្បីជួបនឹង

ព្រះអង្គក្នុងអាកាសវេហាស៍ ហើយយើងនឹងស្ថិតនៅ ជាមួយព្រះអម្ចាស់រហូតតទៅ។ ដូច្នេះ សូមបងប្អូនយកពាក្យទាំងនេះ មកសម្រាលទុក្ខគ្នាទៅវិញទៅមក។

**ម**- នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។

**គ**- សូមអរព្រះគុណព្រះអង្គ។

- *នៅស្ងៀមស្ងាត់បន្តិច បន្ទាប់មកស្មូតទំនុកតម្កើង ដែលបង្ហាញពីសេចក្ដីសង្ឃឹម។*

**ទំនុកតម្កើងលេខ ២៧ (២៦)　　បទពាក្យ ៧**

១- ឱ ! ព្រះអម្ចាស់ជាពន្លឺ　　នាមល្បីរន្ទឺព្រះសង្គ្រោះ
មិនឱ្យខ្ញុំខ្លាចនរណាសោះ　　ជាកំពែងខ្ពស់ជួយជីវិត　　។

៤- ខ្ញុំទូលព្រះម្ចាស់នូវសេចក្ដី　　តែមួយគត់ខ្លីឱ្យបានច្បាស់
គឺចង់ស្នាក់នៅដំណាក់ព្រះ　　ឥតមានក្រឡះមួយជីវិត　　។

៧- ឱ ! ព្រះម្ចាស់អើយសូមសណ្ដាប់　　ស្នូរខ្ញុំស្រែកប្រាប់ឮលាន់ឡើង
អាណិតឆ្លើយតបកុំឆ្មៃឆ្មើង　　មកខ្ញុំវិញផងកុំកន្ដើយ　　។

៨- ទូលបង្គំនឹកព្រះបន្ទូល　　ព្រះអង្គថ្លែងពោលទុកមកហើយ
ចូរស្វែងរកយើងនឹងបានស្បើយ ខ្ញុំមិនព្រងើយស្វែងរកភ័ក្ត្រ　　។

៩- សូមទ្រង់អាណិតដល់រូបខ្ញុំ　　កុំពួនសង្ងំនៅលួចលាក់
កុំព្រះពិរោធកុំអន់អាក់　　កុំបណ្ដេញអ្នកបម្រើចោល　　។

១៣- ខ្ញុំជឿជាក់ថាខ្ញុំនឹងបាន　　ឃើញសុខក្សេមក្សាន្តមិនអាស្រូវ
មង្គលកើតពីព្រះម្ចាស់នៅ　　ក្នុងលោកតទៅជាមិនខាន　　។

១៤- ចូរទុកចិត្តលើព្រះអម្ចាស់　　ព្រះអង្គជាព្រះដ៏ថ្កើងថ្កាន
ចូរមានកម្លាំងចិត្តក្លាហាន　　នោះអ្នកនឹងមានសុភមង្គល　　។

## ខ- ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

• *រង្វង់ធម្មតា*

**អាលេលូយ៉ា** ! សូមលើកតម្កើងព្រះយេស៊ូ ដែលទ្រង់បានឈ្នះសេចក្តីស្លាប់ ចូរយើងទទួលដោយសប្បាយជីវិតថ្មីពីព្រះអម្ចាស់ **អាលេលូយ៉ា**។

• *រង្វង់អប់រំពិសេស*

*បន្ទរ* ៖ សូមលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ត ព្រះអង្គជាព្រះពន្លឺនៃព្រះជាម្ចាស់ សូមកោតសរសើរព្រះអង្គ។

ឱ! ព្រះជាម្ចាស់ សូមព្រះមេត្តា អាណិតអាសូរ កែប្រែដួងចិត្ត គំនិតយើងខ្ញុំ ដើម្បីទទួលព្រះសង្គ្រោះយើង។

## គ- សូមថ្លែងព្រះគម្ពីរដំណឹងល្អ តាមសន្តៈ យ៉ូហាន *(យហ ១១, ១៧-២៧)*

កាលព្រះយេស៊ូយាងទៅដល់ផ្ទះនាងម៉ារី និងនាងម៉ាថា ព្រះអង្គក៏ជ្រាបថា គេបានដាក់សពលោកឡាសារក្នុងផ្នូរ បួនថ្ងៃហើយ។ ភូមិបេថានី មានចម្ងាយប្រមាណបីគីឡូម៉ែត្រ។ មានជនជាតិយូដាជាច្រើន នាំគ្នាមកជួយរំលែកទុក្ខនាងម៉ាថា និងនាងម៉ារី ក្នុងពេលប្អូនស្លាប់។ កាលនាងម៉ាថាបានដឹងថា ព្រះយេស៊ូយាងមកដល់ នាងក៏ចេញទៅទទួលព្រះអង្គរីឯនាងម៉ារីវិញនាងអង្គុយនៅក្នុងផ្ទះ។នាងម៉ាថាទូលព្រះយេស៊ូថា៖ "លោកម្ចាស់ប្រសិនបើលោកបាននៅទីនេះ ប្អូននាងខ្ញុំមិនស្លាប់ទេ។ ប៉ុន្តែឥឡូវនេះនាងខ្ញុំដឹងថា បើលោកសុំអ្វីពីព្រះជាម្ចាស់ក៏ដោយ ព្រះអង្គមុខជាប្រទានឱ្យមិនខាន"។ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ "ប្អូននាងនឹងរស់ឡើងវិញ"។ នាងទូលទៅព្រះអង្គវិញថា៖ "នាងខ្ញុំដឹងហើយនៅថ្ងៃចុងក្រោយបំផុត កាលណាមនុស្សស្លាប់នឹងរស់ឡើងវិញ ប្អូននាងខ្ញុំក៏នឹងរស់ឡើងវិញដែរ"។ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖"ខ្ញុំហ្នឹងហើយ ដែលប្រោសមនុស្សឱ្យរស់ឡើងវិញ ខ្ញុំនឹងផ្តល់ឱ្យគេមានជីវិត។

អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន។ រីឯអស់អ្នកដែលកំពុងតែមានជីវិតនៅរស់ ហើយជឿលើខ្ញុំ មិនស្លាប់សោះឡើយ តើនាងជឿសេចក្ដីនេះឬទេ?"។ នាងម៉ាថាទូលព្រះអង្គថា៖ "បពិត្រព្រះអម្ចាស់ ! ខ្ញុំម្ចាស់ជឿថាព្រះអង្គពិតជាព្រះគ្រីស្ដ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយពិតជាព្រះអង្គដែលត្រូវយាងមកក្នុងពិភពលោកនេះមែន!"។

ច- នេះជាព្រះបន្ទូលដំណឹងល្អ របស់ព្រះយេស៊ូគ្រីស្ដជាអម្ចាស់ !

គ- សូមកោតសរសើរព្រះគ្រីស្ដ។

**ឃ- ធម្មទេសនា**

**៤- ពាក្យអង្វរសាកល**

ច- ពេលនេះសូមបងប្អូនតាំងចិត្តអធិដ្ឋាន ទូលអង្វរព្រះអម្ចាស់ សូមព្រះអង្គពង្រឹងជំនឿរបស់យើងទាំងអស់គ្នា។ សូមទ្រង់ព្រះមេត្តាទទួលវិញ្ញាណក្ខ័ន្ធ .......... (ឈ្មោះជាគ្រីស្ដបរិស័ទ) ដែលបានចែកឋានទៅហើយ សូមព្រះអង្គប្រោសប្រទានឱ្យ.................. (ឈ្មោះជាគ្រីស្ដបរិស័ទ) រស់នៅរួមជាមួយព្រះអង្គអស់កល្បជានិច្ចផង។

*បន្ទរ ៖* កូនសូមស្រែកហៅ អស់ពីដួងចិត្ត សូមព្រះអម្ចាស់ ស្ដាប់សម្លេងកូន។

គ- ១- បពិត្រព្រះបិតា ប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង ! សូមទ្រង់ព្រះមេត្តាអាណិតអាសូរ ........ (ឈ្មោះជាគ្រីស្ដបរិស័ទ) ដែលបានចែកឋានទៅហើយ សូមព្រះអង្គលើកលែងទោសទាំងប៉ុន្មានរបស់គាត់ ហើយសូមទទួលគាត់នៅស្ថានបរមសុខរួមជាមួយព្រះអង្គផង។

២- បពិត្រព្រះអម្ចាស់ ជាព្រះបិតា! សូមព្រះអង្គសម្រាលទុក្ខក្រុមគ្រួសារ ញាតិសន្ដានរបស់ ...... (ឈ្មោះជាគ្រីស្ដបរិស័ទ)។ សូមពង្រឹងជំនឿរបស់ពួកគាត់ ឱ្យមានសេចក្ដីសង្ឃឹមជានិច្ច លើព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គផង។

៣- បពិត្រព្រះអម្ចាស់ជាព្រះបិតា! សូមព្រះអង្គអាណិតអាសូរដល់បងប្អូនយើងខ្ញុំ ដែលកំពុងកើតទុក្ខព្រួយនៅថ្ងៃនេះ សូមឱ្យពួកគាត់បានធូរស្បើយ សូមបំភ្លឺចិត្តគំនិតឱ្យពួកគាត់ យល់ពីទិសដៅនិងពីអត្ថន័យនៃជីវិតរបស់ខ្លួនផង។

៤- បពិត្រព្រះអម្ចាស់ជាព្រះបិតា! សូមព្រះអង្គប្រោសប្រណីដល់យើងខ្ញុំ ដែលមកជួបជុំគ្នានៅពេលនេះ។ សូមពង្រឹងជំនឿយើងខ្ញុំ ចំពោះព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ។ សូមឱ្យយើងខ្ញុំមានចិត្តសុភាពរាបសា សូមឱ្យយើងខ្ញុំជឿសង្ឃឹម និងស្រឡាញ់តាមគំរូរបស់ព្រះនាងម៉ារី និងផ្ញើជីវិតទាំងស្រុងលើព្រះគ្រីស្តក្នុងគ្រប់កាលៈទេសៈផង។

៥- បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ ! ព្រះអង្គមានធម៌មេត្តាករុណាចំពោះមនុស្សគ្រប់ៗរូប ទ្រង់សព្វព្រះហឫទ័យមិនឱ្យនរណាម្នាក់វិនាសឡើយ។ គឺឱ្យមនុស្សទាំងអស់ ទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គនៅស្ថានបរមសុខ។ នៅពេលនេះ សូមទ្រង់ព្រះមេត្តាទទួលពាក្យអង្វររបស់យើងខ្ញុំ សូមទទួលវិញ្ញាណក្ខន្ធ........ (ឈ្មោះជាគ្រីស្តបរិស័ទ) ឱ្យរស់នៅរួមជាមួយព្រះអង្គ និងសូមព្រឹងងជំនឿយើងខ្ញុំផង។

យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

## ៥- ពាក្យអធិដ្ឋាន

៥- សូមបងប្អូនតាំងចិត្តអធិដ្ឋាន។

បពិត្រព្រះអម្ចាស់ជាព្រះបិតា ! ព្រះអង្គមានធម៌មេត្តាករុណាចំពោះមនុស្សគ្រប់ៗរូប ទ្រង់មិនសព្វព្រះហឫទ័យឱ្យនរណាម្នាក់វិនាសឡើយ គឺទ្រង់សព្វព្រះហឫទ័យឱ្យមនុស្សទាំងអស់ ទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គនៅស្ថានបរមសុខ។ សូមទ្រង់ព្រះមេត្តាទទួលពាក្យ អង្វររបស់យើងខ្ញុំនៅពេលនេះ

សូមទទួលវិញ្ញាណក្ខន្ធ ........ (ឈ្មោះជាគ្រីស្តបរិស័ទ) ឱ្យរស់នៅរួមជាមួយព្រះអង្គ និងសូមពង្រឹងជំនឿយើងខ្ញុំផង។

យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

► *លោកបូជាចារ្យ និងក្រុមញាតិសាលោហិតប្រោះទឹកព្រះពរលើសព។*

**ច-** ប្រោះទឹកព្រះពរលើសពនេះជាសញ្ញាបញ្ជាក់ថា... (ឈ្មោះជាគ្រីស្តបរិស័ទ) មានជីវិតថ្មី ដ៏ពេញលេញរួមជាមួយព្រះបិតា តាំងពីពេលគាត់ទទួលអគ្គសញ្ញាជ្រមុជទឹក។

**ច-** បពិត្រព្រះអម្ចាស់ដ៏មានតេជានុភាពសព្វប្រការ និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច។ ព្រះអង្គបានប្រោសយើងខ្ញុំឱ្យទៅជាបុត្រធីតារបស់ព្រះអង្គ នៅពេលនេះ យើងខ្ញុំសូមរួមជាមួយព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញហៅព្រះអង្គថា៖

ឱ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !

សូមសម្តែងព្រះបារមី ឱ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ

សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់ សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ

បានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ។

សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។

សូមអត់ទោសឱ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោស

ឲ្យអស់អ្នក ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។

សូមកុំបណ្តោយឱ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។

តែសូមរំដោះយើងខ្ញុំ ឱ្យរួចពីមារកំណាច។ *អាម៉ែន។*

## ៦- ធម៌ បពិត្រព្រះនាងម៉ារី

**ម**- យើងពឹងលើព្រះនាងម៉ារី ជួយអង្វរព្រះអម្ចាស់ឱ្យ ....... (ឈ្មោះជាគ្រីស្តបរិស័ទ)

**រួមគ្នា**- *បពិត្រព្រះនាងម៉ារី !*

ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់

សូមព្រះនាងមានអំណរសប្បាយ។

ព្រះអង្គគង់ជាមួយនាង ព្រះអង្គបានប្រទានពរដល់នាង លើសស្ត្រីទាំងឡាយ ហើយទ្រង់ក៏ប្រទានពរ ដល់បុត្រព្រះនាងដែរ។

*ឱ! សន្តីម៉ារី ជាមាតាព្រះអម្ចាស់ !*

សូមជួយអង្វរព្រះអង្គ ឱ្យយើងខ្ញុំជាអ្នកបាប នៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង។ *អាម៉ែន។*

## ៧- ធម៌ សូមកោតសរសើរ

**រួមគ្នា**- សូមកោតសរសើរ

ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ

ដែលព្រះអង្គគង់នៅ តាំងពីដើមរៀងមក

ហើយជាដរាបតរៀងទៅ។ *អាម៉ែន។*

*►ពេលលើកសពដាក់ក្នុងមឈូស សូមសូត្រទំនុកតម្កើង*

### ទំនុកតម្កើងលេខ ១៤២ (១៤១)

១- កូនសូមស្រែកទូល អស់ពីដួងចិត្ត សូមព្រះអម្ចាស់ ស្តាប់សម្លេងកូន ។

២- ទំនួញអង្វរ ចំពោះព្រះភ័ក្ត្រ កូនសូមក្រាបទូល អស់ទុក្ខវេទនា ។

| | | | | |
|---|---|---|---|---|
| ៣- ទាំងក្ដីសោកា | និងបារម្ភព្រួយ | សូមព្រះអង្គជួយ | រំលែកទុក្ខកូន | ។ |
| ៤- គ្រាព្រលឹងកូន | ហៀបនឹងរលត់ | ភាពខ្មៅងងឹត | ស្រោបជិតឱ៉ា | ។ |
| ៥- នេះគឺអន្ទាក់ | សត្រូវប៉ុនប៉ង | ប្រាថ្នាសាកល្បង | ស្ទាក់គ្រប់ជំហាន | ។ |
| ៦- តែព្រះអម្ចាស់ | ទ្រង់ឈ្វេងយល់សព្វ | អស់ច្រកងងិត | ដែលកូនវង្វេង | ។ |
| ៧- គ្មាននរជនណា | ជាអ្នកស្ដាប់ជាក់ | គ្មានជនណាម្នាក់ | រវល់នឹងកូន | ។ |
| ៨- កូនអស់សង្ឃឹម | អស់ក្ដីពឹងពាក់ | តែព្រះអម្ចាស់ | នៅទតមកកូន | ។ |
| ៩- ឱ! ព្រះអង្គអើយ | កូនសូមចូលជ្រក | ពឹងទីជម្រក | នៃម្លប់ចេស្ដា | ។ |
| ១០-សូមទ្រង់សណ្ដាប់ | នូវពាក្យទំនួញ | ដ្បិតកូនធ្លាក់ខ្លួន | លំបាកពេកក្រៃ | ។ |
| ១១-សូមព្រះអម្ចាស់ | ជួយរំដោះកូន | ដ្បិតមារសត្រូវ | ខ្លាំងពេកកន្លង | ។ |
| ១២-សូមជួយចម្លង | ព្រលឹងកូនផុត | ពីក្ដីងងឹត | ឱ្យឃើញពន្លឺ | ។ |
| ១៣-ដោយព្រះគុណនេះ | កូនសូមសច្ចា | ថាមិនបំភ្លេច | បារមីចេស្ដា | ។ |
| ១៤-ដោយព្រះអំណោយ | ស្រោចស្រង់ព្រលឹង | កូនសូមរំពឹង | លើព្រះអង្គហើយ | ។ |

**ច**- សូមព្រះអម្ចាស់គង់ជាមួយបងប្អូន។

**គ**- ហើយជាមួយលោកផង។

**ច**- សូមព្រះដ៏មានតេជានុភាពសព្វប្រការ ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ទទួល .... (ឈ្មោះជា គ្រីស្ដបរិស័ទ) ឱ្យរស់នៅរួមជាមួយព្រះអង្គ ហើយសូមព្រះអង្គប្រទានព្រះពរឱ្យអស់បងប្អូន ដែលនៅទីនេះផង។

**គ**- *អាម៉ែន។*

**ច**- សូមបងប្អូនអញ្ជើញឱ្យបានសុខសាន្ត។

**គ**- សូមអរព្រះគុណព្រះអម្ចាស់។

# ៥ ពិធីដង្ហែសព ចេញពីផ្ទះទៅព្រះវិហារ

## ១- ពិធីប្រារព្ធ

**ទំនុកតម្កើងលេខ ២៣ (២២)　　បទ ភាគគតិ**

| | | | |
|---|---|---|---|
| ១- ព្រះអង្គទ្រង់ប្រោស | មេត្តាសន្តោស | គ្មានលស់មួយគ្រា | ទ្រង់បានប្រទាន |
| នូវភោជន៍អាហារ | ឱ្យខ្ញុំសុខា | នៅក្បែរព្រះអង្គ | ។ |
| ២- ព្រះអង្គទ្រង់ជួយ | ណែនាំលើកស្ទួយ | និងជួយតម្រង់ | តាមគន្លងធម៌ |
| ដ៏ភ្លឺត្រចង់ | ព្រះនាមព្រះអង្គ | បានល្បីថ្កើងថ្កាន | ។ |
| ៣- ទោះបីរូបខ្ញុំ | ជួបអន្តរាយធំ | ទាំងអម្បាលម៉ាន | ក៏មិនខ្លាចដែរ |
| ដ្បិតរូបខ្ញុំមាន | ព្រះជួយឱ្យបាន | សុខសាន្តនិរន្តរ៍ | ។ |
| ៤- ខ្ញុំសែនរីករាយ | ក្រាបបង្គំថ្វាយ | ថ្លែងអំណរគុណ | ដ្បិតទ្រង់ប្រទាន |
| ឱ្យឈ្នះទុរជន | ជានិច្ចនិរន្តរ៍ | គ្រប់កាលទាំងអស់ | ។ |
| ៥- ព្រះអង្គតែងផ្តល់ | សុភមង្គល | ដោយក្តីសប្បុរស | ខ្ញុំសូមគោរព |
| បម្រើដោយស្មោះ | រហូតដល់អស់ | អាយុសង្ខារ | ។ |
| ៦- រាល់ពេលថ្ងៃយប់ | ខ្ញុំជ្រកក្រោមម្លប់ | នៃព្រះចេស្តា | ក្រោមព្រះបារមី |
| ប្រណីមេត្តា | វិសេសថ្លៃថ្លា | របស់ព្រះអង្គ | ។ |
| ៧- សិរីជោគជ័យ | បវរសួស្តី | រុងរឿងត្រចង់ | សូមថ្វាយបង្គំ |
| ឆ្ពោះព្រះត្រៃអង្គ | ទ្រង់គង់យូរលង់ | អស់កល្បជានិច្ច | ។ |

## ២- ពាក្យអធិដ្ឋាន

ង- សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះជាម្ចាស់ សូមទ្រង់ព្រះមេត្តាអាណិតអាសូរ ............. (ឈ្មោះជាគ្រីស្តបរិស័ទ) ដែលចែកស្ថាននេះ។ សូមព្រះអង្គបើកទ្វារនៃស្ថានបរមសុខឱ្យគាត់ជាអ្នកបម្រើព្រះអង្គ និងសូមប្រោសប្រទានឱ្យគាត់បានសេចក្តីសុខសាន្ត និងបានអំណរសប្បាយដ៏ពេញលេញ រួមជាមួយអស់អ្នកដែលចូលក្នុងព្រះរាជ្យព្រះអង្គរួចហើយ សូមឱ្យយើងខ្ញុំទាំងអស់គ្នាដែលរស់នៅក្នុងលោកនេះ ចេះលើកទឹកចិត្តគ្នាទៅវិញទៅមក ដោយជំនឿ និងដោយសេចក្តីស្រឡាញ់ រហូតដល់ថ្ងៃដែលព្រះយេស៊ូគ្រីស្តទ្រង់យាងត្រឡប់មកវិញ។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

# ៦ អភិបូជា ពេលសពតម្កល់នៅក្នុងព្រះវិហារ

## ១- ពិធីប្រារព្ធ

►*សូមដុតទៀនព្រះជ័យនៅជិតអាសនៈ ជានិមិត្តរូបនៃការរស់ឡើងវិញរបស់ព្រះគ្រីស្ត។*

►*សូមក្រុមគ្រួសារសព យកក្រណាត់ស មកគ្របលើមឈូសគ្រីស្តបរិស័ទគោរពសពដោយស្លៀមស្វាត់ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ*

►*លោកបូជាចារ្យស្វាគមន៍ក្រុមគ្រួសារសព និងគ្រីស្តបរិស័ទ*

►*លោកបូជាចារ្យពន្យល់អត្ថន័យក្រណាត់ស។*

ម- ក្រណាត់សជាសញ្ញាបង្ហាញថា តាំងពីថ្ងៃទទួលអគ្គសញ្ញាជ្រមុជទឹក ........... (ឈ្មោះជាគ្រីស្តបរិស័ទ) បានទទួលជីវិតថ្មី ដែលជាព្រះជន្មផ្ទាល់របស់ព្រះជាម្ចាស់ និងរស់នៅក្នុងឋានៈជាបុត្រធីតារបស់ព្រះអង្គ។

►*អានវិយោគកថា ឬ ប្រវត្តិសង្ខេបរបស់សព (ប្រសិនបើមាន)*

- ឱ ! ព្រះយេស៊ូជាអម្ចាស់ ដែលព្រះបិតាបានចាត់ឱ្យយាងមកព្យាបាល និងសង្គ្រោះមនុស្សលោក សូមអាណិតអាសូរយើងខ្ញុំ។

<u>ឆ្លើយ</u>៖ *សូមអាណិតអាសូរយើងខ្ញុំ។*

- ឱ! ព្រះគ្រីស្ត ដែលយាងមកហៅអស់អ្នកបាប សូមអាណិតអាសូរយើងខ្ញុំ។

<u>ឆ្លើយ</u>៖ *សូមអាណិតអាសូរយើងខ្ញុំ។*

- ឱ ! ព្រះយេស៊ូជាអម្ចាស់ ដែលគង់ខាងស្តាំព្រះបិតា ដើម្បីជួយអង្វរព្រះអង្គឱ្យយើងខ្ញុំ សូមអាណិតអាសូរយើងខ្ញុំ។

<u>ឆ្លើយ</u>៖ *សូមអាណិតអាសូរយើងខ្ញុំ។*

## ២- ពាក្យអធិដ្ឋាន

**ម-** សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះអម្ចាស់ជាព្រះបិតា ! ព្រះអង្គមិនសព្វព្រះហឫទ័យបណ្តោយឱ្យមនុស្សលោកវិនាសអន្តរាយឡើយ គឺទ្រង់សព្វព្រះហឫទ័យឱ្យមនុស្សមានជីវិត ដោយសារព្រះបុត្រាតែមួយរបស់ព្រះអង្គវិញ។ សូមទ្រង់ព្រះមេត្តាប្រោសអស់អ្នក គោរពថ្វាយបង្គំព្រះបុត្រា ដែលប្រសូតជាមនុស្ស បានទទួលជីវិតថ្មីពីព្រះអង្គផង។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ដែលគង់នៅ និងសោយរាជ្យ រួមជាមួយព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធ អស់កល្បជាអង្វែងតរៀងទៅ។ *អាម៉ែន។*

## ៣- ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

### ក- សូមថ្លែងលិខិតរបស់គ្រីស្តទូតប៉ូល ផ្ញើជូនគ្រីស្តបរិស័ទក្រុងរ៉ូម

*(រ ៦,៣-៥, ៨-៦ )*

បងប្អូនមិនជ្រាបទេឬ យើងទាំងអស់គ្នាដែលបានទទួលពិធីជ្រមុជទឹក ដើម្បីរួមជាមួយ ព្រះគ្រីស្តយេស៊ូនោះ គឺយើងបានជ្រមុជរួមជាមួយព្រះអង្គដែលសោយទិវង្គត។

ហេតុនេះ ដោយពិធីជ្រមុជទឹក ដើម្បីរួមស្លាប់ជាមួយព្រះអង្គ យើងដូចជាបានចូលទៅក្នុងផ្នូររួមជាមួយព្រះអង្គដែរ។ ដូច្នេះព្រះគ្រីស្ដមានព្រះជន្មរស់ឡើងវិញ ដោយសារសិរីរុងរឿងរបស់ព្រះបិតាយ៉ាងណា យើងក៏រស់នៅតាមរបៀបថ្មីយ៉ាងនោះដែរ។ ប្រសិនបើយើងបានរួមស្លាប់ជាមួយព្រះអង្គ ដែលសោយទិវង្គត យើងក៏នឹងបានរួមជាមួយព្រះអង្គដែលមានព្រះជន្មរស់ឡើងវិញដែរ។ ដូច្នេះ ប្រសិនបើយើងរួមស្លាប់ជាមួយព្រះគ្រីស្ដ យើងក៏ជឿថា យើងនឹងមានជីវិតរួមជាមួយព្រះអង្គដែរ ព្រោះយើងដឹងថាព្រះគ្រីស្ដដែលរស់ឡើងវិញនោះ ទ្រង់លែងសោយទិវង្គតហើយមច្ចុរាជគ្មាន អំណាចលើព្រះអង្គទៀតទេ ដ្បិតព្រះអង្គបានសោយទិវង្គតនោះ គឺសោយទិវង្គតឱ្យបានរួចផុតពីអំណាចបាបម្ដងជាសូរេច។

**ច**- នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់

**គ**- សូមអរព្រះគុណព្រះអង្គ។

**ទំនុកតម្កើងលេខ ១៦ (១៥) បទពាក្យ ៧**

- ឱ! ព្រះជាម្ចាស់ដ៏ឧត្ដម សូមការពារខ្ញុំឱ្យសុខសាន្ត
  ដ្បិតទូលបង្គំសូមផ្ញើប្រាណ ជ្រកក្រោមទីស្ថានម្លប់បារមី ។

- ខ្ញុំសូមទូលថ្វាយព្រះម្ចាស់ថា ព្រះអង្គពិតជាអម្ចាស់ថ្លៃ
  ក្រៅពីព្រះអង្គឥតមានអ្វី ផ្ដល់មង្គលជ័យគ្រាអាសន្ន ។

- បពិត្រព្រះអម្ចាស់ឧត្ដម ព្រះអង្គជាចំណែកស្រស់ស្រោយ
  មត៌កនៃខ្ញុំឥតក្លែងក្លាយ ផ្ដល់អ្វីទាំងឡាយតាមប្រាថ្នា ។

- ព្រះអង្គប្រទានកេរមត៌ក វិសេសឥតអាក់ដ៏ថ្លៃថ្លា
  មកទូលបង្គំខ្ញុំនេះណា ជាកេរអស្ចារ្យប្រសើរផុត ។

| | | | |
|---|---|---|---|
| - | ខ្ញុំនឹកដល់ព្រះអម្ចាស់ជាប់ | ដែលជាទម្លាប់ទ្រង់គង់កៀរ | |
| | ខាងស្ដាំរូបខ្ញុំឥតប្រួលប្រែ | ខ្ញុំមិនបែកបែរញាប់ញ័រឡើយ | ។ |
| - | ដ្បិតព្រះអង្គមិនបោះបង់ខ្ញុំ | ឱ្យរងទុក្ខធំស្លាប់សោតសល់ | |
| | ព្រះអង្គក៏មិនបណ្ដោយដល់ | សពបម្រើផ្ទាល់ស្អុយរលួយ | ។ |
| - | ព្រះអង្គបង្ហាញផ្លូវជីវិត | ឱ្យខ្ញុំឃើញពិតគ្មានភ័យព្រួយ | |
| | ដោយព្រះអង្គគង់នៅជាមួយ | នោះខ្ញុំគ្មានព្រួយអរសប្បាយ | ។ |
| - | ដោយព្រះអង្គគង់នៅខាងស្ដាំ | ជាប់ជាប្រចាំមិនជិនណាយ | |
| | ទូលបង្គំសែនអរសប្បាយ | អស់កល្បវែងឆ្ងាយតរៀងទៅ | ។ |

## ខ- ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

● *រដូវធម្មតា*

**អាលេលូយ៉ា** ! សូមលើកតម្កើងព្រះយេស៊ូ ដែលទ្រង់បានឈ្នះសេចក្ដីស្លាប់ ចូរយើងទទួលដោយសប្បាយ ជីវិតថ្មីពីព្រះអម្ចាស់ **អាលេលូយ៉ា**។

● *រដូវអប់រំពិសេស*

*បន្ទរ ៖* សូមលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ត ព្រះអង្គជាព្រះពន្លឺនៃព្រះជាម្ចាស់ សូមកោតសរសើរព្រះអង្គ។

ឱ! ព្រះជាម្ចាស់ សូមព្រះមេត្តា អាណិតអាសូរ កែប្រែដួងចិត្ត គំនិតយើងខ្ញុំ ដើម្បីទទួលតាមព្រះសង្គ្រោះយើង។

## គ- សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្តៈ យ៉ូហាន *( យហ ១៤,១-៧ )*

ព្រះយេស៊ូមានព្រះបន្ទូលថា៖ "កុំរន្ធត់ចិត្តធ្វើអ្វី អ្នករាល់គ្នាជឿលើព្រះជាម្ចាស់ ហើយសុំជឿលើខ្ញុំផង។ ក្នុងដំណាក់របស់ព្រះបិតាខ្ញុំ មានលំនៅជាច្រើន។ បើពុំដូច្នោះ

ទេ ខ្ញុំមិនបានប្រាប់អ្នករាល់គ្នាថា ខ្ញុំទៅរៀបចំកន្លែងទុកឱ្យអ្នករាល់គ្នាឡើយ។ ពេលខ្ញុំទៅរៀបចំកន្លែងទុកឱ្យអ្នករាល់គ្នាហើយ ខ្ញុំនឹងត្រឡប់មកវិញ យកអ្នករាល់គ្នាទៅជាមួយខ្ញុំ ដើម្បីឱ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅ។ ឯកន្លែងដែលខ្ញុំទៅនោះ អ្នករាល់គ្នាក៏ស្គាល់ផ្លូវទៅដែរ"។ លោកថូម៉ាសទូលព្រះអង្គថា៖ "បពិត្រព្រះអម្ចាស់ ធ្វើដូចម្ដេចឱ្យយើងខ្ញុំអាចស្គាល់ផ្លូវទៅបាន បើយើងខ្ញុំមិនដឹងថាព្រះអង្គយាងទៅទីណាផងនោះ"។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ "ខ្ញុំហ្នឹងហើយជាផ្លូវ ជាសេចក្ដីពិត និងជាជីវិត។ គ្មាននរណាម្នាក់អាចទៅកាន់ព្រះបិតាបានឡើយ លើកលែងតែទៅតាមរយៈខ្ញុំ។ បើអ្នករាល់គ្នាស្គាល់ខ្ញុំ អ្នករាល់គ្នាក៏ស្គាល់ព្រះបិតារបស់ខ្ញុំដែរ។ ឥឡូវនេះ អ្នករាល់គ្នាស្គាល់ព្រះអង្គហើយ ព្រមទាំងបានឃើញព្រះអង្គថែមទៀតផង"។

**ម**- នេះជាព្រះបន្ទូលដំណឹងល្អ របស់ព្រះយេស៊ូគ្រីស្ដជាអម្ចាស់ !

**គ**- សូមកោតសរសើរព្រះគ្រីស្ដ។

### ឃ- ធម្មទេសនា

## ៤- ពាក្យអង្វរសាកល

*បន្ទរ ៖* កូនសូមស្រែកហៅ អស់ពីដួងចិត្ត សូមព្រះអម្ចាស់ ស្ដាប់សម្លេងកូន។

១- បពិត្រព្រះបិតា ដ៏វិសុទ្ធបំផុត ! ព្រះអង្គសព្វព្រះហឫទ័យជ្រើសរើស ............ (ឈ្មោះជាគ្រីស្ដបរិស័ទ) ឱ្យធ្វើជាបុត្រធីតារបស់ព្រះអង្គ។ ពេលមានជីវិតរស់នៅ ជួនកាលភាពទន់ខ្សោយបានអូសទាញគាត់ឱ្យប្រព្រឹត្ដខុសនឹងព្រះហឫទ័យព្រះអង្គ ប៉ុន្ដែ ព្រះអង្គតែងតែទំនុកបម្រុងនិងគាំទ្រគាត់ជានិច្ច។ សូមទ្រង់ព្រះមេត្ដាលើកលែងទោស ទាំងប៉ុន្មានរបស់គាត់ សូមប្រោសទទួលគាត់ក្នុងស្ថានបរមសុខរួមជាមួយព្រះអង្គផង។ កូនសូមទូលអង្វរ...

២- បពិត្រព្រះអម្ចាស់ជាព្រះបិតា ! ព្រះអង្គមានព្រះហឫទ័យស្រឡាញ់មនុស្សលោកយ៉ាងក្រៃលែង។ សូមទ្រង់ព្រះមេត្ដាសម្រាលទុក្ខដល់ក្រុមគ្រួសារ សាច់

សាលោហិតរបស់ ....... (ឈ្មោះជាគ្រីស្តបរិស័ទ) ដែលកំពុងសោកសង្រេង នេះ។ សូមប្រទានជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ឱ្យពួកគាត់។ សូមប្រោសឱ្យពួកគាត់ផ្ញើជីវិតទាំងស្រុងលើព្រះអង្គ និងធ្វើជាសាក្សីដ៏ពិតប្រាកដអំពីជីវិតថ្មី ដែលព្រះគ្រីស្តបានប្រទានឱ្យយើងខ្ញុំផង។ កូនសូមទូលអង្វរព្រះអង្គ...

៣- បពិត្រព្រះបិតា ដ៏វិសុទ្ធបំផុត ! ព្រះអង្គសព្វព្រះហឫទ័យត្រាស់ហៅយើងខ្ញុំឱ្យស្គាល់ព្រះបុត្រាព្រះអង្គ។ សូមទ្រង់ព្រះមេត្តា ប្រោសយើងខ្ញុំឱ្យរួចពីចំណងបាប ដើម្បីឱ្យយើងខ្ញុំមានសេរីភាពដ៏ពិតប្រាកដ។ សូមប្រោសយើងខ្ញុំឱ្យយកចិត្តទុកដាក់ ស្វែងរកសេចក្តីពិតដោយចិត្តសុភាពរាបសា។ សូមពង្រឹងជំនឿយើងខ្ញុំ និងសូមប្រោសយើងខ្ញុំ ឱ្យផ្ញើជីវិតទាំងស្រុងលើព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ គ្រប់ពេលវេលាផង។ កូនសូមទូលអង្វរព្រះអង្គ...

## ៦- ពិធីលើកតម្កើងព្រះកាយព្រះគ្រីស្ត

### ក- ថ្វាយតង្វាយ

### *តង្វាយភក្តី*

១- យើងសូមថ្វាយតង្វាយ ដែលកើតមកពីការងារនៃមនុស្ស
ទៅដល់ព្រះម្ចាស់សូមសព្វហឫទ័យ សូមសព្វហឫទ័យទទួលតង្វាយយើងខ្ញុំ។

*បន្ទរ ៖* សូមសព្វព្រះហឫទ័យ ចំពោះតង្វាយនេះផង
ដែលយើងរាល់គ្នាថ្វាយទៅ ដោយចិត្តសុភាព និងជ្រះថ្លា។

២- បើសិនទ្រង់សព្វហឫទ័យ ក៏សូមប្រណីលើកលែងកំហុស
ដែលយើងបានធ្វើក្នុងពេលមួយថ្ងៃ ឱ្យបានជ្រះស្អាតដូចជាតង្វាយយើងខ្ញុំ។

៣ - តង្វាយយើងខ្ញុំថ្វាយនេះ ចំនួនតិចតួចស្តួចស្តើងពេកក្រៃ
មិនធួននឹងក្តីអាក្រក់យើងខ្ញុំ ប៉ុន្តែយើងថ្វាយ ដោយចិត្តថ្លាសប្បុរស។

ម- សូមបងប្អូនតាំងចិត្តអធិដ្ឋានរួមជាមួយគ្នា ក្នុងពេលថ្វាយសក្ការបូជារបស់ព្រះសហគមន៍ទាំងមូល។

គ- សូមឱ្យសក្ការបូជានេះ បានគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងឱ្យមនុស្សលោកបានទទួលការសង្គ្រោះពីព្រះអង្គផង។

## ខ- ពាក្យថ្វាយតង្វាយ

បពិត្រព្រះអម្ចាស់ជាព្រះបិតា ! ព្រះអង្គស្រឡាញ់មនុស្សលោកយ៉ាងក្រៃលែង រហូតដល់ចាត់ព្រះបុត្រាព្រះអង្គ ឱ្យយាងមករួមរស់ជាមួយយើងខ្ញុំ។ យើងខ្ញុំសូមផ្ញើជីវិតទាំងស្រុងទៅលើព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ។ សូមជម្រះចិត្តគំនិតយើងខ្ញុំក្នុងអភិបូជានេះផង។

ម - សូមព្រះអម្ចាស់គង់ជាមួយបងប្អូន
គ - ហើយជាមួយលោកផង។

ម - សូមលើកចិត្តថ្វាយព្រះអង្គ
គ - យើងលើកចិត្តថ្វាយព្រះអង្គហើយ។

ម - សូមអរព្រះគុណព្រះអង្គម្ចាស់
គ - ពិតជាការគួរណាស់ ហើយប្រពៃផង។

## គ- ធម៌លើកតម្កើង

បពិត្រព្រះបិតាដ៏វិសុទ្ធបំផុត ! យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ជាព្រះដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ហើយដែលមានតេជានុភាពសព្វ

ប្រការ។ ព្រះអង្គប្រោសព្រះគ្រីស្តឱ្យមានព្រះជន្មរស់ឡើងវិញ។ ព្រះអង្គក៏ប្រោសយើងខ្ញុំឱ្យមានសេចក្តីសង្ឃឹមជានិច្ច។ ទោះបីយើងខ្ញុំពុំអាចជៀសផុតពីសេចក្តីស្លាប់ក៏ដោយ ក៏យើងខ្ញុំនៅតែមានសេចក្តីសង្ឃឹមយ៉ាងមាំថា នឹងមានជីវិតអស់កល្បជានិច្ច រួមជាមួយព្រះគ្រីស្តដែរ។ យើងខ្ញុំជឿជាក់ថា ពេលយើងខ្ញុំទទួលមរណភាព យើងខ្ញុំមិនបាត់បង់ជីវិតរហូតទេ គឺជីវិតយើងខ្ញុំស្ថិតនៅអស់កល្បជានិច្ចរួមជាមួយព្រះបិតា។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត និងសន្តបុគ្គលទាំងឡាយ ដើម្បីប្រកាសថា៖

*ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !*
*ព្រះអង្គជាម្ចាស់ លើពិភពលោកទាំងមូល*
*មេឃ និង ដី ពោរពេញដោយសិរីរុងរឿង របស់ព្រះអង្គ។*
*ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត*
*សូមកោតសរសើរព្រះអង្គ ដែលយាងមកក្នុងនាមនៃព្រះជាម្ចាស់*
*ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត។*

បពិត្រព្រះជាម្ចាស់ ! ព្រះអង្គពិតជាវិសុទ្ធមែន សត្វលោកទាំងអស់ដែលទ្រង់បានបង្កើតមក សូមថ្វាយបង្គំលើកតម្កើងព្រះអង្គ។ មានតែព្រះអង្គទេ ដែលប្រោសប្រទានឱ្យសត្វលោកមានជីវិត និងបានវិសុទ្ធដោយតេជានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ដោយសារព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ព្រះអង្គតែងតែបង្រួបបង្រួមបុត្រធីតារបស់ព្រះអង្គ ឱ្យទៅជាប្រជារាស្ត្រព្រះអង្គ ដើម្បីលើកតង្វាយដ៏វិសុទ្ធថ្វាយព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទីក្នុងសកលលោក។

ហេតុនេះហើយ យើងខ្ញុំសូមអង្វរព្រះអង្គ
សូមប្រទានវិញ្ញាណដ៏វិសុទ្ធមកញ៉ាំងតង្វាយទាំងនេះឱ្យបានវិសុទ្ធ
និងបានទៅជាព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រីស្ត

ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ដែលព្រះអង្គបានផ្ដាំឱ្យយើងខ្ញុំ ថ្វាយអភិបូជានេះ។

នៅរាត្រីដែលគេបញ្ជូនព្រះយេស៊ូទៅសោយទុក្ខលំបាក

ព្រះអង្គធ្វើពិធីជប់លៀងជាមួយសាវ័កទាំងឡាយ

ទ្រង់យកនំប៉័ងមកកាន់

អរព្រះគុណព្រះបិតា ទ្រង់ប្រសិទ្ធព្រះពរ

ហើយបែងចែកប្រទានឱ្យក្រុមសាវ័ក

ទាំងមានព្រះបន្ទូលថា

**"សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា"។**

នៅគ្រាចុងក្រោយនៃពិធីជប់លៀង

ព្រះអង្គធ្វើតាមរបៀបដដែល

ទ្រង់លើកពែងស្រាឡើង

អរព្រះគុណព្រះបិតា ហើយប្រទានឱ្យក្រុមសាវ័ក

ទាំងមានព្រះបន្ទូលថា៖

**"សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**

**នេះជាលោហិតរបស់ខ្ញុំ**

**ដែលចងសម្ពន្ធមេត្រីថ្មី និងគង់វង្សអស់កល្បជានិច្ច**

**ហើយដែលត្រូវបូជា ដើម្បីលើកលែងទោសរំដោះបាប**

**ឱ្យអ្នករាល់គ្នា និងឱ្យមនុស្សទាំងឡាយ។**

**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ"។**

ម. សូមអញ្ជើញសម្ដែងជំនឿចំពោះព្រះយេស៊ូគ្រីស្ត ដែលទ្រង់បានរំដោះយើង។

គ្រ. *ឱ! ព្រះអម្ចាស់អើយ យើងខ្ញុំសូមប្រកាសថា ៖*

*ព្រះអង្គសោយទិវង្គត ហើយទ្រង់មានព្រះជន្មរស់ឡើងវិញមែន*

*យើងខ្ញុំសូមប្រកាសនៅពេលនេះ*

*ហើយរហូតដល់ពេលព្រះអង្គយាងមកវិញ។*

បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ

យើងខ្ញុំនាំគ្នានឹករឭកដល់ព្រះបុត្រាព្រះអង្គ

សោយទិវង្គតដើម្បីសង្គ្រោះយើងខ្ញុំ

ទ្រង់មានព្រះជន្មរស់ឡើងវិញយ៉ាងរុងរឿង និងយាងឡើងស្ថានបរមសុខ

ហើយយើងខ្ញុំក៏ទន្ទឹងរង់ចាំព្រះបុត្រាព្រះអង្គ យាងត្រឡប់មកវិញ។

យើងខ្ញុំសូមថ្វាយសក្ការបូជាដ៏ពិសិដ្ឋនេះ ដែលផ្ដល់ជីវិត

ដើម្បីថ្លែងអំណរព្រះគុណព្រះអង្គ

សូមព្រះអង្គទ្រង់ព្រះមេត្តាទទួលសក្ការបូជាពីព្រះសហគមន៍

ទុកជាសក្ការបូជារបស់ព្រះបុត្រាព្រះអង្គ

ដែលបានសម្រុះសម្រួលយើងខ្ញុំ ជាមួយព្រះអង្គ។

ពេលយើងខ្ញុំទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គ

ទាំងបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធនេះ

សូមព្រះអង្គប្រោសប្រទានឱ្យយើងខ្ញុំ បានមូលផ្ដុំគ្នាជាធ្លុងតែមួយ

និងមានចិត្តគំនិតតែមួយ ក្នុងអង្គព្រះគ្រីស្ត។

សូមព្រះវិញ្ញាណដ៏វិសុទ្ធណែនាំយើងខ្ញុំ ឱ្យថ្វាយខ្លួនចំពោះព្រះបិតាទុកជាតង្វាយគង់វង្សអស់កល្បជានិច្ច ដើម្បីឱ្យយើងខ្ញុំ បានទទួលជីវិតនៅស្ថានបរមសុខ រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី ជាព្រះមាតាព្រះយេស៊ូគ្រីស្ត ជាមួយអស់គ្រីស្តទូត និងមរណសាក្សី (ជាមួយសន្តៈ ឬ សន្តី...) ព្រមទាំងជាមួយសន្តបុគ្គលទាំងឡាយ ដែលតែងតែជួយអង្វរព្រះអង្គឱ្យយើងខ្ញុំ។

ឱ ! ព្រះបិតាជាអម្ចាស់យើងខ្ញុំអើយ ដោយសក្ការបូជាដែលសម្រុះសម្រួលយើងខ្ញុំជាមួយព្រះអង្គ សូមទ្រង់ប្រោសប្រទានឱ្យមនុស្សលោកទទួលការសង្គ្រោះ និងសេចក្ដីសុខសាន្ត។ សូមពង្រឹងជំនឿ និងសេចក្ដីស្រឡាញ់របស់បុត្រធីតាព្រះអង្គ ឱ្យបានមាំមួននៅនាលោកនេះ សូមថែរក្សាសម្ដេចប៉ាបព្រះនាម ............. លោក ..............ជាអភិបាលព្រះសហគមន៍យើងខ្ញុំ និងលោកអភិបាលព្រះសហគមន៍នានា ក្នុងសកលលោកទាំងមូល អស់លោកបូជាចារ្យ អស់លោកឧបដ្ឋាក និងប្រជារាស្ត្រទាំងអស់របស់ព្រះអង្គផង។

ឱ ! ព្រះបិតាដ៏មានព្រះហឫទ័យមេត្តាករុណា សូមទ្រង់ព្រះសណ្ដាប់ពាក្យអង្វររបស់បុត្រធីតា ដែលបាបជួបជុំគ្នាគោរពបម្រើព្រះអង្គនៅទីនេះ។ សូមទ្រង់ប្រទានឱ្យអស់បុត្រធីតាព្រះអង្គ ដែលខ្វាត់ខ្វាយបានចូលរួមជាមួយព្រះអង្គផង។

*ឱ! ព្រះបិតាយើងខ្ញុំអើយ សូមព្រះអង្គប្រោសប្រណីដល់បុត្រធីតាព្រះអង្គ...... (ឈ្មោះជាគ្រីស្តបរិស័ទ) ដែលទ្រង់បានត្រាស់ហៅឱ្យលាចាកលោកទៅឯព្រះអង្គ។ ដោយអគ្គសញ្ញាជ្រមុជទឹក គាត់បានចូលរួមជាមួយព្រះបុត្រាព្រះអង្គដែលបានសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ។ សូមទ្រង់ព្រះមេត្តាប្រោសគាត់ ឱ្យទទួលជីវិតអស់កល្បជានិច្ចរួមជាមួយព្រះបុត្រាព្រះអង្គ យើងខ្ញុំក៏សូមឱ្យគាត់បានរស់ឡើងវិញដូចព្រះបុត្រាព្រះអង្គយ៉ាងនោះដែរ។*

*សូមព្រះអង្គទ្រង់ព្រះមេត្តាអាណិតអាសូរដល់អស់បងប្អូនយើងខ្ញុំ ដែលបានទទួលមរណភាព និងដល់បុគ្គលទាំអស់ដែលបានលាចាកលោកនេះទៅហើយ។ សូមទ្រង់*

*ទទួលបុគ្គលទាំងនោះក្នុងព្រះរាជ្យព្រះអង្គ ដែលយើងខ្ញុំសង្ឃឹមថា និងបានពោរពេញដោយបរមសុខអស់កល្បជានិច្ច។ នៅពេលនោះព្រះអង្គនឹងប្រោសប្រទាន ឱ្យយើងខ្ញុំចាកផុតអំពីទុក្ខសោក ដ្បិតនៅពេលដែលយើងខ្ញុំយល់ព្រះភ័ក្ត្រព្រះអង្គយ៉ាងជាក់ស្តែងនោះ យើងខ្ញុំនឹងមានភាពរុងរឿងដូចព្រះអង្គអស់កល្បជានិច្ច ហើយនឹងថ្វាយបង្គំលើកតម្កើងព្រះអង្គឥតឈប់ឈរ រួមជាមួយព្រះគ្រីស្តជាអម្ចាស់យើងខ្ញុំ គឺដោយសារព្រះគ្រីស្តនេះហើយ បានជាព្រះអង្គប្រទានព្រះអំណោយទានគ្រប់បែបយ៉ាងដល់ពិភពលោកទាំងមូល។*

សូមព្រះអង្គ ព្រះមេត្តាអាណិតអាសូរដល់អស់បងប្អូនយើងខ្ញុំ ដែលបានទទួលមរណភាព និងដល់បុគ្គលទាំងអស់ដែលបានលាចាកលោកនេះទៅហើយ សូមទទួលបុគ្គលទាំងនេះក្នុងព្រះរាជ្យព្រះអង្គ។ យើងខ្ញុំក៏សង្ឃឹមថា នឹងបានពោរពេញដោយបរមសុខទាំងអស់គ្នា អស់កល្បជានិច្ច ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ គឺដោយសារព្រះគ្រីស្តនេះហើយ បានជាព្រះអង្គប្រទានព្រះអំណោយគ្រប់បែបយ៉ាងដល់សកលលោកទាំងមូល។

**ឱ ! ព្រះបិតា ដ៏មានតេជានុភាពសព្វប្រការ**
**គឺដោយសារព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត**
**រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង**
**បានជាយើងខ្ញុំ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ**
**អស់កល្បជាអង្វែងតរៀងទៅ។**

**គ**- អាម៉ែន។

**ម**- ដូចព្រះយេស៊ូបានប្រៀនប្រដៅយើងខ្ញុំ ហើយតាមព្រះបញ្ជារបស់ព្រះអង្គ យើងខ្ញុំហ៊ានសូត្រថា៖

ឱ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !

សូមសម្តែងព្រះបារមី ឱ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ
សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់ សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ
បានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ។

សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។
សូមអត់ទោសឱ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោស
ឲ្យអស់អ្នក ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។
សូមកុំបណ្តោយឱ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។
តែសូមរំដោះយើងខ្ញុំ ឱ្យរួចពីមារកំណាច។ *អាម៉ែន។*

ឱ ! ព្រះអម្ចាស់យើងខ្ញុំអើយ ! សូមទ្រង់ព្រះមេត្តាជួយយើងខ្ញុំ ឱ្យរួចពីអន្តរាយគ្រប់បែបយ៉ាង សូមទ្រង់ប្រោសប្រទានឱ្យយើងខ្ញុំរស់នៅបានសេចក្តីសុខសាន្ត និងរួចចាកពីអំពើបាបជានិច្ច កុំឱ្យយើងខ្ញុំជួបប្រទះនឹងទុក្ខលំបាកណាឡើយ។

យើងខ្ញុំមានសង្ឃឹមយ៉ាងមាំថា នឹងបានបរមសុខ ហើយយើងខ្ញុំក៏រង់ចាំព្រះយេស៊ូគ្រីស្ត ជាព្រះសង្គ្រោះ ទ្រង់យាងត្រឡប់មកវិញ។

*ដ្បិតព្រះអង្គគ្រងរាជ្យ ទ្រង់មានឫទ្ធានុភាព និងសិរីរុងរឿង អស់កល្បជាអង្វែងតរៀងទៅ។*

ឱ ! ព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំអើយ ! ព្រះអង្គមានព្រះបន្ទូលទៅកាន់សាវ័កទាំងឡាយថា "ខ្ញុំផ្តល់ឱ្យអ្នករាល់គ្នាបានសេចក្តីសុខសាន្ត គឺសេចក្តីសុខសាន្តរបស់ខ្ញុំ"។ សូមទ្រង់ព្រះមេត្តា កុំប្រកាន់ទោសរបស់យើងខ្ញុំឡើយ តែសូមទ្រង់ឈ្វេងយល់នូវជំនឿរបស់ព្រះសហគមន៍ព្រះអង្គវិញ។ សូមទ្រង់ប្រោសប្រទានឱ្យព្រះសហគមន៍ បានប្រកបដោយសេចក្តីសុខសាន្ត និងបានមូលផ្តុំគ្នាជាធ្លុងតែមួយផង។ ព្រះអង្គទ្រង់មានព្រះជន្មគង់នៅ និងសោយរាជ្យ អស់កល្បជាអង្វែងតរៀងទៅ។ *អាម៉ែន។*

ច- សូមឱ្យបងប្អូនបានសេចក្តីសុខសាន្តជានិច្ចពីព្រះអម្ចាស់។

គ- សូមឱ្យលោក បានសេចក្តីសុខសាន្តនោះផង។

ច- សូមបងប្អូនបង្ហាញសញ្ញានៃសេចក្តីសុខសាន្តរវាងគ្នានឹងគ្នា។

*ឱ! ព្រះយេស៊ូ ដែលរំដោះបាបមនុស្សលោកីយ៍ សូមអាណិតអាសូរយើងខ្ញុំ*

*ឱ! ព្រះយេស៊ូ ដែលរំដោះបាបមនុស្សលោកីយ៍ សូមអាណិតអាសូរយើងខ្ញុំ*

*ឱ! ព្រះយេស៊ូ ដែលរំដោះបាបមនុស្សលោកីយ៍ សូមប្រទានសេចក្តីសុខសាន្តឱ្យយើងខ្ញុំ។*

ច- *នេះជាព្រះកាយព្រះគ្រីស្ត ដែលរំដោះបាបមនុស្សលោកីយ៍ អស់អ្នកណាដែលទទួលព្រះកាយព្រះអង្គ ក្នុងពិធីជប់លៀងនេះ ពិតជាបានសុភមង្គល។*

គ- *ឱ ! ព្រះអម្ចាស់អើយ ! ខ្ញុំមិនសមនឹងទទួលព្រះអង្គទេ*
*តែសូមព្រះអង្គមានព្រះបន្ទូល តែមួយព្រះឱស្ឋមក*
*នោះព្រលឹងខ្ញុំ នឹងបានជាសះស្បើយ។*

## ៧- ពិធីទទួលព្រះកាយ

*បន្ទរ ៖* ខ្ញុំជាអាហារដែលមានជីវិត ចុះមកពីស្ថានបរមសុខអើយ អ្នកណាបានបរិភោគអាហារនេះហើយ នឹងបានរស់នៅអស់កល្បជានិច្ចអើយ។

១- ចូរយើងឱនកាយក្រាបថ្វាយបង្គំ ព្រះសញ្ញាយ៉ាងពិសិដ្ឋឧត្តម
គឺព្រះកាយានៃព្រះយេស៊ូ ទ្រង់ចងសម្ពន្ធមេត្រីថ្មី
ទោះបីភ្នែកយើងខ្ញុំមើលមិនឃើញ តែយើងជឿទ្រង់គង់ទីនេះ។

២- ចូរយើងឱនកាយក្រាបថ្វាយបង្គំ អរព្រះគុណព្រះគ្រីស្តថ្លៃថ្លាឧត្តម
ព្រះអង្គទ្រង់គង់ក្នុងព្រះកាយា ពោរពេញដោយក្តីអាថ៌កំបាំង

យើងខ្ញុំសូមថ្វាយកាយនិងវាចា ទាំងចិត្តសែនរីករាយសប្បាយ។

៣- ចូរយើងថ្លែងឡើងសិរីថ្កុំថ្កើង មានដល់ព្រះបិតាព្រះបុត្រា
ចូរយើងសរសើរពេញទាំងមេឃដី តេជានុភាពព្រះអង្គ
សូមក្តីថ្កុំថ្កើងរុងរឿងរស្មី មានដល់ព្រះវិញ្ញាណវិសុទ្ធ។

## ៨- ពាក្យអររព្រះគុណ

បពិត្រព្រះអម្ចាស់ជាព្រះបិតា ! ព្រះអង្គមានព្រះហឫទ័យស្មោះត្រង់ជានិច្ច។ ព្រះអង្គបានសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គ តាមព្រះបន្ទូលសន្យា។ សូមទ្រង់ព្រះមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំ សូមឱ្យថ្ងៃណាមួយ យើងខ្ញុំអាចទទួលសុភមង្គលដ៏ពេញលក្ខណៈតាមព្រះបន្ទូលសន្យានេះផង។

# ៧ ពិធីលាសពចុងក្រោយ

**១- ពិធីប្រារព្ធ**

► *លោកបូជាចារ្យចុះពីអាសនៈ ទៅឆ្ពោះសព។*

**២- ពាក្យអធិដ្ឋាន**

**ច-** សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតា នៅពេលដែល.......... (ឈ្មោះជាគ្រីស្តបរិស័ទ) លាចាកពីលោកនេះ ទៅក្នុងសេចក្ដីសង្ឃឹម ដោយព្រះគ្រីស្តបានបូជាព្រះជន្ម ហើយព្រះអង្គមានជ័យជម្នះលើសេចក្ដីស្លាប់ យើងខ្ញុំទាំងអស់គ្នាសូមទូលអង្វរព្រះអង្គ សូមទ្រង់ព្រះមេត្តាប្រោស............ (ឈ្មោះជាគ្រីស្តបរិស័ទ) ឱ្យគាត់សម្រាកយ៉ាងសុខសាន្តផង។

► *នៅពេលស្ងៀមស្ងាត់នេះ ចូរយើងរឭកដល់កិច្ចការ និងអ្វីៗដែល.......... (ឈ្មោះជាគ្រីស្តបរិស័ទ) បានធ្វើចំពោះយើង នឹងចំពោះព្រះជាម្ចាស់។*

**ទំនុកតម្កើងលេខ ៥១ (៥០) បទភាគគតិ**

- ឱ! ព្រះអម្ចាស់ ប្រសើរពេកណាស់ ដោយធម៌មេត្តា សូមទ្រង់អាណិត
  លើកលែងទោសា ឱ្យខ្ញុំផងណា ដោយអនុគ្រោះ ។

- សូមទ្រង់ឧបត្ថម្ភ ចិត្តគំនិតខ្ញុំ ឱ្យបានខ្ពង់ខ្ពស់ ឱ្យបានបរិសុទ្ធ
  ផុតចាកបាបគ្រោះ រួចពីទុក្ខទោស សព្វគ្រប់ប្រការ ។

| | | | |
|---|---|---|---|
| - ខ្ញុំសូមសារភាព | នូវអំពើបាប | តូចធំយ៉ាងណា | ហើយតែងនឹកចាំ |
| រាល់ទិនទិវា | បាបគ្រប់ប្រការ | ដែលខ្ញុំប្រព្រឹត្ត | ។ |
| - ទាំងការអាក្រក់ | អំពើលាមក | ឬក្តីទុច្ចរិត | ដែលខ្ញុំបានធ្វើ |
| និងបានប្រព្រឹត្ត | ជាកំហុសពិត | ចំពោះព្រះភ័ក្ត្រ | ។ |

*►លោកបូជាចារ្យឈរនៅមុខសពរួមជាមួយគ្រីស្តបរិស័ទសូត្រធម៌*

ម- បពិត្រព្រះបិតាជាអម្ចាស់ យើងរឭកដល់ ....... (ឈ្មោះជាគ្រីស្តបរិស័ទ) ជាបងប្អូនយើងខ្ញុំ និងសូមអង្វរព្រះអង្គថា៖

គ- សូមឱ្យ..... (ឈ្មោះជាគ្រីស្តបរិស័ទ) បានស្គាល់សេចក្តីសុខសាន្តអស់កល្បជានិច្ច នៅក្បែរព្រះអង្គ

*<u>បន្ទ</u>៖ សូមឱ្យ....... (ឈ្មោះជាគ្រីស្តបរិស័ទ) សម្រាកដោយសុខសាន្តអស់កល្បជាអង្វែងតរៀងទៅ។*

សូមព្រះគ្រីស្តទទួល...... (ឈ្មោះជាគ្រីស្តបរិស័ទ) ឲ្យនៅស្ថានបរមសុខជាមួយអស់អ្នកដែល បានលាចាកលោកនេះទៅហើយ

*<u>បន្ទ</u>៖ សូមឱ្យ....... (ឈ្មោះជាគ្រីស្តបរិស័ទ) សម្រាកដោយសុខសាន្តអស់កល្បជាអង្វែងតរៀងទៅ។*

សូមឱ្យ...... (ឈ្មោះជាគ្រីស្តបរិស័ទ) ទទួលសុភមង្គល រួមជាមួយសន្តបុគ្គលទាំងឡាយផង

*<u>បន្ទ</u>៖ សូមឱ្យ....... (ឈ្មោះជាគ្រីស្តបរិស័ទ) សម្រាកដោយសុខសាន្តអស់កល្បជាអង្វែងតរៀងទៅ។*

សូមឱ្យ...... (ឈ្មោះជាគ្រីស្តបរិស័ទ) បានយល់ព្រះភក្ត្ររបស់ព្រះអង្គ និងទទួលអំណរសប្បាយអស់កល្បជានិច្ច

*<u>បន្ទ</u>៖ សូមឱ្យ....... (ឈ្មោះជាគ្រីស្តបរិស័ទ) សម្រាកដោយសុខសាន្តអស់កល្បជាអង្វែងតរៀងទៅ។*

បពិត្រព្រះបិតា នៅពេលដែលយើងខ្ញុំទូលអង្វរព្រះអង្គសម្រាប់....(ឈ្មោះជាគ្រីស្តបរិស័ទ) សូមព្រះអង្គ ព្រះមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំ ហើយនាំយើងខ្ញុំឱ្យទៅព្រះបិតាផង

*<u>បន្ទ</u>៖ សូមឱ្យ....... (ឈ្មោះជាគ្រីស្តបរិស័ទ) សម្រាកដោយសុខសាន្តអស់កល្បជាអង្វែងតរៀងទៅ។*

*►លោកបូជាចារ្យដោតធូបឬដុតកំញានជាកិច្ចគោរពវិញ្ញាណក្ខន្ធ។*

## ៣- ពាក្យអធិដ្ឋាន

ច- សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតា ដ៏មានព្រះហឫទ័យមេត្តាករុណាយ៉ាងក្រៃលែង ! យើងខ្ញុំសូមប្រគល់វិញ្ញាណក្ខន្ធ.......... (ឈ្មោះជាគ្រីស្តបរិស័ទ) ជាបងប្អូនយើងខ្ញុំ ទៅក្នុងព្រះហស្តព្រះអង្គហើយ។ យើងខ្ញុំមានសង្ឃឹមយ៉ាងមាំថា នៅថ្ងៃចុងក្រោយ......... (ឈ្មោះជាគ្រីស្តបរិស័ទ) នឹងមានជីវិតរស់ឡើងវិញ រួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ។ សូមទ្រង់ព្រះមេត្តាស្តាប់ពាក្យអង្វររបស់យើងខ្ញុំ សូមបើកទ្វារនៃស្ថានបរមសុខឱ្យអ្នកបម្រើនេះ និងសូមឱ្យយើងខ្ញុំទាំងអស់គ្នា ដែលរស់នៅក្នុងលោកនេះ ចេះលើកទឹកចិត្តគ្នាទៅវិញទៅមក ដោយជំនឿ និងដោយសេចក្តីស្រឡាញ់ រហូតដល់ថ្ងៃដែលព្រះយេស៊ូគ្រីស្ត ទ្រង់យាងត្រឡប់មកវិញ។ នៅពេលនោះ យើងខ្ញុំនឹងរស់នៅរួមជាមួយព្រះអង្គ និងជាមួយ.. (ឈ្មោះជាគ្រីស្តបរិស័ទ) ជាបងប្អូនរបស់យើងខ្ញុំនេះដែរ។

យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះអង្គ

ទ្រង់មានព្រះជន្មគង់នៅនិងសោយរាជ្យរួមជាមួយព្រះបិតានិងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ។

## ៤- ពិធីប្រោសទឹកព្រះពរលើសព

- ► *លោកបូជាចារ្យធ្វើព្រះពរលើទឹក ហើយប្រោសទឹកព្រះពរលើសព*
- ► *ទឹកជាសញ្ញាសម្គាល់ថា បុគ្គលនេះមានជីវិតថ្មី តាំងពីថ្ងៃគាត់ទទួលអគ្គសញ្ញាជ្រមុជទឹក*
- ► *លោកបូជាចារ្យអញ្ជើញក្រុមគ្រួសារ និងញាតិមិត្តដុតធូបនិងប្រោសទឹកព្រះពរលើសព*
- ► *ធូបជួយរំឭកយើងថា រូបកាយរបស់យើងជាព្រះដំណាក់របស់ព្រះជាម្ចាស់។*

### ទំនុកតម្កើងលេខ ៥១ ( ៥០ )        បទ ភាគគតិ

| | | | |
|---|---|---|---|
| - ឱ! ព្រះអម្ចាស់ | ប្រសើរពេកណាស់ | ដោយធម៌មេត្តា | សូមទ្រង់អាណិត |
| លើកលែងទោសា | ឱ្យខ្ញុំផងណា | ដោយអនុគ្រោះ | ។ |
| - សូមទ្រង់ឧបត្ថម្ភ | ចិត្តគំនិតខ្ញុំ | ឱ្យបានខ្ពង់ខ្ពស់ | ឱ្យបានបរិសុទ្ធ |
| ផុតចាកបាបគ្រោះ | រួចពីទុក្ខទោស | សព្វគ្រប់ប្រការ | ។ |
| - ខ្ញុំសូមសារភាព | នូវអំពើបាប | តូចធំយ៉ាងណា | ហើយតែងនឹកចាំ |
| រាល់ទិនទិវា | បាបគ្រប់ប្រការ | ដែលខ្ញុំប្រព្រឹត្ត | ។ |
| - ទាំងការអាក្រក់ | អំពើលាមក | ឬក្តីទុច្ចរិត | ដែលខ្ញុំបានធ្វើ |
| និងបានប្រព្រឹត្ត | ជាកំហុសពិត | ចំពោះព្រះភក្ត្រ | ។ |
| - ទ្រង់វិនិច្ឆ័យ | ព្រមទាំងកាត់ក្តី | ដោយធម៌សច្ចៈ | ចំពោះបាបកម្ម |
| ដែលខ្ញុំជំពាក់ | ពីអតីតៈ | ដោយយុត្តិធម៌ | ។ |

- ទ្រង់សព្វហឫទ័យ នឹងជនប្រុសស្រី មានចិត្តស្មោះស សូមទ្រង់ទូន្មាន
  នូវសច្ចធម៌ ឱ្យស្គាល់ផ្លូវល្អ នៅក្នុងលោកីយ៍ ។

- សូមទ្រង់កម្ចាត់ ព្រមទាំងបំបាត់ អំពើអប្រិយ៍ សូមឱ្យរូបខ្ញុំ
  ប្រាសចាកទុក្ខភ័យ អស់គ្រោះចង្រៃ ស្គាល់ក្ដីភិរម្យ ។

- សូមទ្រង់មេត្តា លើកលែងទោសា របស់រូបខ្ញុំ សូមទ្រង់រំដោះ
  ឱ្យបានសុខុម ហើយសូមទ្រង់កុំ បោះបង់ចោលខ្ញុំ ។

- ឱ! ព្រះជាម្ចាស់ សូមទ្រង់ជម្រះ ចិត្តគំនិតខ្ញុំ ឱ្យស្អាតបរិសុទ្ធ
  ម៉ត់ចត់សុខុម អង់អាចឧត្តម មាំមួនដរាប ។

- សូមព្រះអង្គកុំ បោះបង់រូបខ្ញុំ ជាជនទទន់ទាប ឱ្យឃ្លាតចេញឆ្ងាយ
  ដូចអ្នកមានបាប សូមរស់ដរាប ក្បែរព្រះឧត្ដម ។

- ឯព្រះវិញ្ញាណ វិសុទ្ធថ្កើងថ្កាន ថ្លៃថ្លាឧត្ដម សូមទ្រង់មេត្តា
  កុំចាកចោលខ្ញុំ ឱ្យនៅក្រៀមក្រំ តែឯងឯកា ។

- សូមទ្រង់ប្រទាន ឱ្យរូបខ្ញុំមាន សទ្ធាជ្រះថ្លា ឱ្យបានសប្បាយ
  រីករាយចិន្ដា ដោយទ្រង់មេត្តា សង្គ្រោះគាំទ្រ ។

- សូមថ្លែងជោគជ័យ ដ៏អស្ចារ្យក្រៃ នៃព្រះបិតា សូមកោតបារមី
  នៃព្រះបុត្រា សូមកោតចេស្ដា នៃព្រះវិញ្ញាណ ។

## ៥- ពិធីទទួលព្រះពរ

**ច-** សូមព្រះអម្ចាស់គង់ជាមួយបងប្អូន

**គ**- ហើយជាមួយលោកផង។

**ច**- សូមព្រះបិតាដ៏មានតេជានុភាពសព្វប្រការ

ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ប្រទានព្រះពរឱ្យអស់បងប្អូន។

**គ**- *អាម៉ែន។*

**ច**- សូមអស់បងប្អូនអញ្ជើញឱ្យបានសុខសាន្ត។

**គ**- សូមអរព្រះគុណព្រះអម្ចាស់។

## ៦- ពាក្យថ្លែងអំណរគុណ

*►ក្រុមគ្រួសារសព អំណរគុណដល់អង្គប្រជុំ (ប្រសិនបើមាន)*

*(ក្រុមគ្រួសារ ដកយកក្រណាត់សចេញពីមឈូស)*

## ៧- រំកិលសពពីព្រះវិហារទៅឈាបនដ្ឋាន ឬទីបញ្ចុះសព

# ៨ ពិធីនៅឈាបនដ្ឋាន ឬ ទីបញ្ចុះសព

## ១- ពិធីប្រារព្ធ

- ►*ដើរប្រទក្សិណ ៣ ជុំ*
- ►*រំកិលសពដាក់លើមេរុ ឬ នៅមាត់រណ្ដៅ*
- ►*ក្រុមគ្រួសារ និងញាតិមិត្តដុតធូបគោរពសព ។*

**រួមគ្នា-** ក្នុងព្រះនាម ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ

**ទំនុកតម្កើងរបស់លោកតាសាការី** ( **បទពាក្យ ៧** )

| | | |
|---|---|---|
| ៦៨- | សូមលើកតម្កើងព្រះអម្ចាស់<br>ជាតិអ៊ីស្រាអែលដែលធ្លាប់ស្មោះ | ប្រសើរពេកណាស់ព្រះរបស់<br>យាងមករំដោះរាស្ត្រព្រះអង្គ ។ |
| ៦៩- | ទ្រង់បានប្រទានព្រះសង្គ្រោះ<br>ពីក្នុងចំណោមព្រះញាតិវង្ស | ដែលមានឫទ្ធិខ្ពស់ដ៏ត្រចង់<br>ដាវីឌជាពង្សបម្រើជាក់ ។ |
| ៧០- | ព្រះម្ចាស់ប្រទានព្រះសង្គ្រោះ<br>ដូចបានសន្យាតាមរយៈ | យើងមិនដែលលោះមិនដែលលាក់<br>ព្យាការីស្ម័គ្រកាលគ្រាមុន ។ |
| ៧១- | ព្រះអង្គសង្គ្រោះយើងឱ្យរួច<br>និងផុតពីពួកទុរជន | ចេញពីអំណាចខ្លាំងលើសលន់<br>ដែលធ្លាប់ជិះជាន់ស្អប់ខ្ពើមយើង ។ |

៧២- ព្រះអង្គសម្តែងព្រះហឫទ័យ ករុណាប្រណីមិនឆ្មៃឆ្មើង
ដល់បុព្វបុរសដែលតម្កើង សម្ព័ន្ធព្រះអង្គមិនភ្លេចសោះ ។

៧៣- គឺព្រះអង្គហើយបានសន្យា ពាក្យពិតសត្យាមិនចន្លោះ
នឹងអប្រាហាំបុព្វបុរស ដូនតាយើងនោះដូច្នេះថា ។

៧៤- ទ្រង់នឹងរំដោះយើងឱ្យរួច ផុតពីអំណាចខ្មាំងឫស្យា
ដើម្បីយើងអាចក្រាបកាយា វន្ទាគ្រប់គ្រាគ្មានភ័យភិត ។

៧៥- ព្រមទាំងឱ្យយើងបានរស់នៅ ឥតមានអាស្រូវដោយសុចរិត
ជារៀងរាល់ថ្ងៃមួយជីវិត គាប់ហឫទ័យពិតព្រះម្ចាស់ថ្លៃ ។

៧៦- ចំណែកឯរូបរបស់កូន ក្លាយខ្លួនមកជាព្យាការី
ព្រោះកូនដើរមុខព្រះម្ចាស់ថ្លៃ រៀបផ្លូវល្អក្រៃថ្វាយព្រះអង្គ ។

៧៧- កូននឹងធ្វើឱ្យអស់ប្រជា រាស្ត្រទាំងអស់គ្នាគេបានដឹង
ថាព្រះសង្គ្រោះគឺព្រះអង្គ ទាំងលើកទោសផងរួចពីបាប ។

៧៨- ព្រះរបស់យើងមានហឫទ័យ ករុណាប្រណីជាដរាប
ទ្រង់ប្រទានថ្ងៃរះរៀងរាប រំដោះរួចបាបយើងពិត ៗ ។

៧៩- សម្រាប់បំភ្លឺដល់អស់អ្នក ដែលបាននៅស្នាក់ទីងងឹត
ព្រមទាំងតម្រង់ផ្លូវជីវិត យើងឆ្ពោះរកពិតក្តីសុខសាន្ត ។

## ២- ធម៌ សូមកោតសរសើរ

**រួមគ្នា-** សូមកោតសរសើរ

ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ

ដែលព្រះអង្គគង់នៅ តាំងពីដើមរៀងមក
ហើយជាដរាបតរៀងទៅ។ *អាម៉ែន។*

## ៣- ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

### ក- សូមថ្លែងលិខិតរបស់គ្រីស្តទូតប៉ូល ផ្ញើជូនគ្រីស្តបរិស័ទក្រុងកូរិនថូស

*(១ករ ១៥,៤២-៤៤. ៤៨-៤៩)*

រូបកាយដែលគេកប់ក្នុងដី ជារូបកាយដ៏ទន់ខ្សោយ រីឯរូបកាយដែលរស់ឡើងវិញ ជារូបកាយប្រកបដោយឫទ្ធានុភាព។ រូបកាយដែលគេកប់ក្នុងដី ជារូបកាយធម្មជាតិ រីឯរូបកាយដែលរស់ឡើងវិញ ជារូបកាយប្រកបដោយព្រះវិញ្ញាណ។ ប្រសិនបើមានរូបកាយធម្មជាតិមែន រូបកាយប្រកបដោយវិញ្ញាណក៏មានដែរ។ អស់អ្នកដែលកើតពីដីក៏មានលក្ខណៈដូចអ្វីៗនៅលើដីនេះ ហើយអស់អ្នកដែលកើតពីស្ថានបរមសុខ ក៏មានលក្ខណៈដូចព្រះអង្គដែលនៅស្ថានបរមសុខដែរ។

**ច**- នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់

**គ**- សូមអរព្រះគុណព្រះអង្គ។

## ៤- ពាក្យអង្វរសាកល

**ច**- យើងខ្ញុំសូមអង្វរព្រះបិតាសម្រាប់បងប្អូនយើងខ្ញុំ ដែលបានទទួលមរណភាពប៉ុន្មានថ្ងៃកន្លងមក

*បន្ទ ៖* សូមព្រះអង្គមេត្តាប្រោសស្តាប់យើងខ្ញុំ

១- បពិត្រព្រះយេស៊ូគ្រីស្តជាអម្ចាស់ ព្រះអង្គបានព្រះកន្សែងនៅពេលលោកឡាសាជាមិត្តសម្លាញ់ របស់ព្រះអង្គទទួលមរណភាព សូមព្រះអង្គព្រះមេត្តាជូតទឹកភ្នែកឱ្យយើងខ្ញុំផង។

២- ព្រះអង្គប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ សូមព្រះអង្គប្រទានជីវិតអស់កល្បជានិច្ចឱ្យ ........ (ឈ្មោះជាគ្រីស្តបរិស័ទ) ផង។

៣- ព្រះអង្គបានជ្រើសរើស .......... (ឈ្មោះជាគ្រីស្តបរិស័ទ) ឱ្យបានទទួលពិធីជ្រមុជទឹក សូមព្រះអង្គប្រទានជីវិតពេញលក្ខណៈជាបុត្រធីតារបស់ព្រះជាម្ចាស់ដល់គាត់ផង។

៤- ពីមុនព្រះអង្គបានប្រទានព្រះកាយរបស់ព្រះអង្គដល់ ........ (ឈ្មោះជាគ្រីស្តបរិស័ទ) សូមព្រះអង្គទទួលគាត់ ឱ្យចូលរួមក្នុងពិធីជប់លៀងនៅឯស្ថានបរមសុខផង។

៥- ព្រះអង្គបានទទួលជ័យជម្នះលើសេចក្តីស្លាប់ ដើម្បីឱ្យយើងមានជីវិត។ ដោយសារព្រះអង្គសេចក្តីស្រឡាញ់មនុស្សទាំងអស់ ព្រះអង្គបានសោយទិវង្គត។ សូមព្រះអង្គប្រទានសេចក្តីសង្ឃឹមឱ្យយើងខ្ញុំផង។

►*អញ្ជើញក្រុមគ្រួសារ និងញាតិមិត្តប្រោះទឹកព្រះពរលើសព។*

## ៥- ពាក្យអធិដ្ឋាន

ម- សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ សូមព្រះអង្គសម្តែងធម៌មេត្តាករុណាដល់អ្នកបម្រើរបស់ព្រះអង្គ គឺ........ (ឈ្មោះជាគ្រីស្តបរិស័ទ) សូមព្រះអង្គថែរក្សាការពារ ....... (ឈ្មោះជាគ្រីស្តបរិស័ទ) ជាអ្នកបាបឱ្យរួចផុតពីសេចក្តីវិនាសអន្តរាយ។ កាលពីគាត់ មានជីវិតនៅឡើយ ដោយសារជំនឿ គាត់បានចូលរួមជាមួយប្រជារាស្ត្ររបស់ព្រះអង្គ ឥឡូវនេះ សូមព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ នាំគាត់ចូលរួមជាមួយសន្តបុគ្គលទាំងឡាយផង។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

# ៩

# ពិធីជូនឡើងសព

# ឬ រំកិលសពចូលក្នុងរណ្ដៅ

**ទំនុកតម្កើងលេខ ១៣០ ( ១២៩ )  បទ ភាកគតិ**

- កូនដង្ហោយហៅ ពីទីជម្រៅ រកព្រះបវរ សូមព្រះសណ្ដាប់
ពាក្យកូនអង្វរ និងសូមថ្វាយពរ ឆ្ពោះម្ចាស់សួគ៌ា ។

- ឱ ! ព្រះសង្គ្រោះ សូមជួយសន្ដោស មនុស្សលោកា កុំចាប់កំហុស
តើមាននរណា រួចពីទោសា ស្ថិតស្ថេរនៅបាន ។

- ចំណែកព្រះអង្គ តែងជួយស្រោចស្រង់ លើកលែងទោសបាន យើងគួរកោតខ្លាច
ព្រះម្ចាស់ថ្កើងថ្កាន ដោយចិត្តក្លាហាន បង្គំបូជា ។

- កូនជឿសង្ឃឹម ត្រេកអរញញឹម អស់ពីចិន្ដា គោរពព្រះអង្គ
កោតខ្លាចចេស្ដា ពឹងព្រះអង្គា ខ្ពង់ខ្ពស់ថ្លាថ្លៃ ។

- ឱ! ព្រលឹងខ្ញុំ ចាំព្រះឧត្ដម ទាំងយប់ទាំងថ្ងៃ ជាងអ្នកឃ្លាំចាំ
មើលបច្ចូសសម័យ ចាំពន្លឺថ្ងៃ ពេលព្រឹកព្រលឹម ។

- ឱ ! ព្រះជាម្ចាស់ ខ្ពង់ខ្ពស់ពេកណាស់ គ្មានអ្វីប្រៀបផ្ទឹម កូនចៅព្រះអង្គ
ត្រេកអរញញឹម មានចិត្តសង្ឃឹម លើព្រះប្រោសលោះ ។

- ដោយសារព្រះអង្គ មកជួយស្រោចស្រង់ ដោយអនុគ្រោះ កូនចៅព្រះអង្គ
ឱ្យផុតបាបគ្រោះ ទ្រង់ជួយរំដោះ ចាកផុតទោសា ។

- សូមថ្លែងជោគជ័យ ប្រសើរថ្លាថ្លៃ អស់ពីចិន្តា ថ្លែងអំណរគុណ ឆ្ពោះព្រះបិតា ទាំងព្រះបុត្រា និងព្រះវិញ្ញាណ ។

## ធម៌ បពិត្រព្រះនាងម៉ារី

**ប**- យើងពឹងលើព្រះនាងម៉ារី ជួយអង្វរព្រះអម្ចាស់ឱ្យ ....... (ឈ្មោះជាគ្រីស្តបរិស័ទ)

**រួមគ្នា**- *បពិត្រព្រះនាងម៉ារី !*

ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់

សូមព្រះនាងមានអំណរសប្បាយ។

ព្រះអង្គគង់ជាមួយនាង ព្រះអង្គបានប្រទានពរដល់នាង លើសស្ត្រីទាំងឡាយ ហើយទ្រង់ក៏ប្រទានពរ ដល់បុត្រព្រះនាងដែរ។

*ឱ! សន្តីម៉ារី ជាមាតាព្រះអម្ចាស់ !*

សូមជួយអង្វរព្រះអង្គ ឱ្យយើងខ្ញុំជាអ្នកបាប នៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង។ *អាម៉ែន។*

**ប**- សូមព្រះយេស៊ូគ្រីស្តជាអម្ចាស់ ដែលមានព្រះជនរស់ឡើងវិញ មេត្តាប្រទានសេចក្តីសុខសាន្តអស់កល្បជានិច្ចដល់ ........ (ឈ្មោះជាគ្រីស្តបរិស័ទ) ផង។

**ប** - ដោយព្រះនាម ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

**គ** - *អាម៉ែន។*

# ១០ ពិធីតម្កល់អដ្ឋិធាតុក្នុងចេតិយ

**១- ពិធីប្រារព្ធ**

**ព្រះគ្រីស្តជាទីសង្ឃឹម**

*បន្ទរ ៖* ព្រះគ្រីស្តជាទីសង្ឃឹម ជាអង្គគាំទ្រនៃជីវិតខ្ញុំ។

១- ទូលបង្គំខ្ញុំ ទៅដល់អាសនៈ ដោយចិត្តរីករាយ សូមវិនិច្ឆ័យ
តាមសប្បុរសភាព ឱ! ព្រះអង្គអើយ ។

២- សូមថ្វាយចិន្តា និងជីវភាព សូមទ្រង់ជម្រះ ឱ្យជ្រះសៅហ្មង
ដើម្បីគាប់គួរ ថ្វាយបុណ្យបូជា ។

៣- នេះខ្ញុំសង្ឃឹម ជឿជាក់ស្រឡាញ់ បម្រើព្រះអង្គ អស់មួយជីវិត
តបស្នងសងគុណ អស់កល្បជានិច្ច ។

**ម-** ដោយព្រះនាម ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

**គ-** អាម៉ែន។

**ម-** សូមព្រះជាម្ចាស់គង់ជាមួយបងប្អូន។

**គ-** ហើយជាមួយលោកផង។

**ម-** សូមព្រះជាម្ចាស់ប្រោសទទួលវិញ្ញាណក្ខ័ន្ធ......... (ឈ្មោះជាគ្រីស្តបរិស័ទ) ឱ្យចូលរួមជាមួយសន្តបុគ្គលទាំងឡាយ ក្នុងសិរីរុងរឿងរបស់ព្រះអង្គផង។

**គ-** សូមឱ្យគាត់បានសម្រាកក្នុងព្រះពន្លឺរបស់ព្រះជាអម្ចាស់ អស់កល្បជាអង្វែងតរៀងទៅ។

ង- សូមព្រះជាម្ចាស់ ប្រោសទទួលវិញ្ញាណក្ខ័ន្ធ......... (ឈ្មោះជាគ្រីស្តបរិស័ទ) ឱ្យចូលរួមជាមួយទេវទូតទាំងឡាយ ក្នុងសិរីរុងរឿងរបស់ព្រះអង្គផង។

ឆ- សូមឱ្យគាត់បានសម្រាកក្នុងព្រះពន្លឺរបស់ព្រះជាអម្ចាស់ អស់កល្បជាអង្វែងតរៀងទៅ។

ង- សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះបិតាដ៏មានព្រះហឫទ័យមេត្តាករុណាយ៉ាងក្រៃលែង ! យើងខ្ញុំសូមប្រគល់វិញ្ញាណក្ខ័ន្ធ............ (ឈ្មោះជាគ្រីស្តបរិស័ទ) ជាបងប្អូនរបស់យើងខ្ញុំទៅក្នុងព្រះហស្តព្រះអង្គហើយ។ យើងខ្ញុំមានសង្ឃឹមយ៉ាងមាំថា នៅថ្ងៃចុងក្រោយ.....(ឈ្មោះជាគ្រីស្តបរិស័ទ) នឹងមានជីវិតរស់ឡើងវិញរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ។ សូមទ្រង់ព្រះមេត្តាស្តាប់ពាក្យអង្វររបស់យើងខ្ញុំ សូមបើកទ្វានៃស្ថានបរមសុខឱ្យអ្នកបម្រើនេះ និងសូមឱ្យយើងខ្ញុំទាំងអស់គ្នាដែលរស់នៅក្នុងលោកនេះ ចេះលើកទឹកចិត្តគ្នាទៅវិញទៅមក ដោយជំនឿ និងដោយសេចក្តីស្រឡាញ់ រហូតដល់ថ្ងៃដែលព្រះយេស៊ូគ្រីស្តទ្រង់យាងត្រឡប់មកវិញ នៅពេលនោះ យើងខ្ញុំនឹងរស់នៅជាមួយព្រះអង្គនិងជាមួយ....... (ឈ្មោះជាគ្រីស្តបរិស័ទ) ជាបងប្អូនរបស់យើងខ្ញុំដែរ។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

## ២- ពិធីប្រោសទឹកព្រះពរលើអដ្ឋិធាតុ

► *លោកបូជាចារ្យធ្វើព្រះពរលើទឹក ហើយប្រោសទឹកព្រះពរលើអដ្ឋិធាតុ*

► *ក្រុមគ្រួសារនិងញាតិមិត្តដុតធូប និងប្រោសទឹកព្រះពរលើអដ្ឋិធាតុ*

► *ទឹកជាសញ្ញាសម្គាល់ថា បុគ្គលនេះមានជីវិតថ្មី តាំងពីថ្ងៃគាត់ទទួលអគ្គសញ្ញាជ្រមុជទឹក*

## ទំនុកតម្កើងលេខ ២៣ ( ២២ )　　បទ ភាកគតិ

១- ព្រះអង្គទ្រង់ប្រោស　មេត្តាសន្ដោស　គ្មានលោះមួយគ្រា　ទ្រង់បានប្រទាន
នូវភោជន៍អាហារ　ឱ្យខ្ញុំសុខា　នៅក្បែរព្រះអង្គ ។

២- ព្រះអង្គទ្រង់ជួយ　ណែនាំលើកស្ទួយ　និងជួយតម្រង់　តាមគន្លងធម៌
ដ៏ភ្លឺត្រចង់　ព្រះនាមព្រះអង្គ　បានល្បីថ្កើងថ្កាន ។

៣- ទោះបីរូបខ្ញុំ　ជួបអន្តរាយធំ　ទាំងអម្បាលម៉ាន　ក៏មិនខ្លាចដែរ
ដ្បិតរូបខ្ញុំមាន　ព្រះជួយឱ្យបាន　សុខសាន្តនិរន្តរ៍ ។

៤- ខ្ញុំសែនរីករាយ　ក្រាបបង្គំថ្វាយ　ថ្លែងអំណរគុណ　ដ្បិតទ្រង់ប្រទាន
ឱ្យឈ្នះទុរជន　ជានិច្ចនិរន្តរ៍　គ្រប់កាលទាំងអស់ ។

៥- ព្រះអង្គតែងផ្តល់　សុភមង្គល　ដោយក្តីសប្បុរស　ខ្ញុំសូមគោរព
បម្រើដោយស្មោះ　រហូតដល់អស់　អាយុសង្ខារ ។

៦- រាល់ពេលថ្ងៃយប់　ខ្ញុំជ្រកក្រោមម្លប់　នៃព្រះចេស្តា　ក្រោមព្រះបារមី
ប្រណីមេត្តា　វិសេសថ្លៃថ្លា　របស់ព្រះអង្គ ។

៧- សិរីជោគជ័យ　បវរសួស្តី　រុងរឿងត្រចង់　សូមថ្វាយបង្គំ
ឆ្ពោះព្រះត្រៃអង្គ　ទ្រង់គង់យូរលង់　អស់កល្បជានិច្ច ។

### ៣- ធម៌ ឱ ! ព្រះបិតាយើងខ្ញុំ

ច- យើងរួមជាមួយព្រះយេស៊ូ ដែលទទួលព្រះជន្មរស់ឡើងវិញ ទូលអង្វរព្រះបិតាថា៖

**រួមគ្នា-** ឱ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !

សូមសម្តែងព្រះបារមី ឱ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ

សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់

សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ

បានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ។

សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។

សូមអត់ទោសឱ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោស

ឲ្យអស់អ្នក ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។

សូមកុំបណ្តោយឱ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។

តែសូមរំដោះយើងខ្ញុំ ឱ្យរួចពីមារកំណាច។ *អាម៉ែន។*

## ៣- ពាក្យអធិដ្ឋានបញ្ចប់

បពិត្រព្រះបិតាដ៏មានធម៌មេត្តាករុណាយ៉ាងក្រៃលែង។ យើងខ្ញុំសូមទូលអង្វរព្រះអង្គ សូមទ្រង់ព្រះមេត្តាទទួលវិញ្ញាណក្ខ័ន្ធ................ (ឈ្មោះជាគ្រីស្តបរិស័ទ) ជាអ្នកបម្រើព្រះអង្គ។ ពេលរស់នៅ គាត់បានផ្ញើជីវិតលើព្រះអង្គ ជំនឿរបស់គាត់នាំគាត់ឱ្យចូលរួមក្នុងប្រជាជនអ្នកជឿ។ ពេលនេះ គាត់បានលាចាកលោកនេះទៅហើយ សូមឱ្យគាត់បានពោរពេញដោយអំណរសប្បាយនៅស្ថានបរមសុខ រួមជាមួយព្រះអង្គផង។ ទោះបីគាត់ បានប្រព្រឹត្តអំពើបាបយ៉ាងណាក៏ដោយ ក៏សូមទ្រង់ព្រះមេត្តាលើកលែងទោសឱ្យគាត់ តាមព្រះហឫទ័យមេត្តាករុណាដ៏លើសលប់របស់ព្រះអង្គផង។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។ *អាម៉ែន។*

► *ញាតិសន្តាន យកអដ្ឋិធាតុទៅតម្កល់ក្នុងចេតិយ*

## ៤- ធម៌ បពិត្រព្រះនាងម៉ារី

**ច-** យើងពឹងលើព្រះនាងម៉ារី ជួយអង្វរព្រះអម្ចាស់ឱ្យ ....... (ឈ្មោះជាគ្រីស្តបរិស័ទ)

**រួមគ្នា-** *បពិត្រព្រះនាងម៉ារី !*

ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់

សូមព្រះនាងមានអំណរសប្បាយ។

ព្រះអង្គគង់ជាមួយនាង ព្រះអង្គបានប្រទានពរដល់នាង លើសស្ត្រីទាំងឡាយ ហើយទ្រង់ក៏ប្រទានពរ ដល់បុត្រព្រះនាងដែរ។

*ឱ! សន្តីម៉ារី ជាមាតាព្រះអម្ចាស់ !*

សូមជួយអង្វរព្រះអង្គ ឱ្យយើងខ្ញុំជាអ្នកបាប នៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង។ *អាម៉ែន។*

## ៥- ពាក្យអធិដ្ឋាន

- *ពេលតម្កល់អដ្ឋិធាតុក្នុងចេតិយ*

យើងខ្ញុំសូមផ្ញើធាតុនេះក្នុងចេតីយ៍ "ដោយយើងខ្ញុំកើតមកពីធូលីដី យើងខ្ញុំក៏ត្រឡប់ទៅជាធូលីដីដែរ" ពេលនេះ សូមឱ្យអ្នកបម្រើរបស់ព្រះអង្គ សម្រាកដោយសេចក្តីសុខនៅក្នុងចេតីយ៍នេះ រហូតដល់ថ្ងៃបុត្រមនុស្សយាងមក ប្រោសរូបកាយមនុស្សលោកឱ្យរស់ឡើងវិញ។ នៅពេលនោះ......... (ឈ្មោះជាគ្រីស្តបរិស័ទ) នឹងឃើញពន្លឺអស់កល្បជានិច្ចនៃស្ថានបរមសុខ ហើយស្ថិតនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ ដែលមានព្រះជន្មគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ។ *អាម៉ែន។*

រៀបសម្រួលឡើងវិញដោយ៖

**គណៈកម្មការពិធីបុណ្យភូមិភាគភ្នំពេញ**

លោកបូជាចារ្យ **ប្រុយណ្ហាភូស**

បងស្រី **អាង លូស៊ី**

លោក **ដួង សាវង់**

លោក **ហ៊ិន សុភា**